Transcript of a DVD released in June 2005 recording a discussion with Chhay Vee and Chum Bun Thoeun on May 29, 1998

# កិច្ចសំភាសន៍ទាក់ទងនឹងការគប់គ្រាប់បែកដៃ នៅមុខរដ្ឋសភាជាតិ នាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៧

*លោក អេង ឆៃអ៊ាង និងលោកស្រី ជូឡុង សូម្ហ៉ា ជាមួយនិង លោក ឆាយ វី និង លោក ជុំ ប៊ុនធឿន*

1- អ៊ាង : ឆាយវីឯងស្គាល់លោក ហ៊ីង ប៊ុនហៀង ពេលណា?

2- ឆាយវី : ស្គាល់ ! អាវ៉ែង មួយភ្លែត ! ខ្ញុំជួបកាលជួបហ្នឹងមិនប្រាប់ខ្ញុំថា បញ្ហាអ្វីមួយហ្នឹងខ្ញុំមិនទាន់ដឹងថារឿងអីៗទេ ប៉ុន្តែជួបនៅពេលដែល លោកហ្នឹងឯង លោកហ្នឹង ហ៊ីង ប៊ុនហៀងក៏មិនដឹង ឬលោកណាក៏មិនដឹងដែរ ខ្ញុំមិនទាន់ស្គាល់គេ

3- អ៊ាង : ពេលនោះអ្នកណាអ្នកនាំឆាយវីឯងមកជួបនឹងហ៊ីងប៊ុនហៀង?

4- ឆាយវី : ខ្ញុំទៅជាមួយលោកនេះ

5- អ៊ាង : ប៉ុន្មានថ្ងៃ មុនថ្ងៃបោកគ្រាប់បែក ?

6- ឆាយវី : កាលពីថ្ងៃ ២៦

7- អ៊ាង : អញ្ចឹង ! នៅពេលជួបនោះអត់ដឹងថា ហ៊ីង ប៊ុនហៀងទេ

8- ឆាយវី : អត់ទេ ! អត់ដឹងទេ ! ព្រោះខ្ញុំអត់ដែលស្គាល់គាត់ផង

9- អ៊ាង : ចុះពេលណាដែលបានដឹងថា គាត់ហ្នឹងជាហ៊ីងប៊ុនហៀង ?

10- ឆាយវី : ពេលហើយ បានគេប្រាប់ថា ហ៊ីង ប៊ុនហៀង ។ ពេលហើយ ពេលគាត់ចេញពីនោះមកវិញ ចេញពីកន្លែងដែលខ្ញុំកំពុងនិយាយការងារហ្នឹង ក៏មិនទាន់និយាយពីរឿងការងារអ្វីមួយដែរគ្រាន់តែទំនាក់ទំនងពីរឿងបញ្ហាពីនេះពីនោះ ព្រោះ អានេះវាមានពីដើមឡើយហ្នឹង មានបញ្ហាការដែលទៅជាមួយនិយាយរឿងទាហានមកពីឥណ្ឌូនេស៊ី រឿងកំម្មង់ដូហើយក៏មាន ពេលគេកំពុងនិយាយអញ្ចឹងខ្ញុំក៏ទំលាក់រឿងនោះមកដោយសារ ដោយសារថ្ងៃ ១៥ ហ៊ីង ប៊ុនហៀងអត់ពាក់ព័ន្ធទេ...

11- អ៊ាង : ប៉ុន្តែក្រោយពីជួបគាត់ហើយ ក្រោយដឹងថា គាត់ហ៊ីងប៊ុនហៀងហើយ តើមានដឹងថាគាត់មានតួនាទីអ្វី មានដឹងទេ ?

12- ឆាយវី : អត់មានដឹងតួនាទីអ្វីទេ

13- អ៊ាង : គ្រាន់តែដឹង ហ៊ីង ប៊ុនហៀង ?

14- ឆាយវី : ដល់គេប្រាប់ហើយ ផុតពីគេហើយ បានគេប្រាប់ថាហ្នឹងហើយហ៊ីង ប៊ុនហៀង ប្រធានអង្គរក្ស ហ៊ុន សែន

15- អ៊ាង : ហើយថ្ងៃ២៦ដែលធឿនឯងទៅទួលក្រសាំងហ្នឹង អូនៃឆាយវីទៅទួលក្រសាំងហ្នឹង ទៅលេងធម្មតា ?

16- ឆាយវី : ទៅលេងធម្មតា

17- អ៊ាង : ឬគេហៅ ?

18- ឆាយវី : អត់ទេ ! ទៅលេងធម្មតា លេងទៅឃើញគេហៅនៅហ្នឹងបណ្តោយ

19- អ៊ាង : បំណងទៅហ្នឹង ទៅលេងពួកម៉ាក ?

20- ឆាយវី : ទៅលេងពួកម៉ាក ពួកម៉ាកធ្វើការនៅកន្លែងហ្នឹង

21- អ៊ាង : ពួកម៉ាកហ្នឹងមាននរណាខ្លះ ?

22- ឆាយវី : អាសុន, អាហាក់ មានច្រើន ខ្ញុំភ្លេចឈ្មោះហើយច្រើន ពួកឆ័ត្រយោង

23- អ៊ាង : ពួកឆ័ត្រយោង ពួកហ្នឹងពេលត្រឡប់មកពីឥណ្ឌូនេស៊ីវិញបានគេរើសចូលអង្គរក្ស គេរើសចូល ឬក៏សុំគេចូល ?

24- ឆាយវី : អត់ទេ ! គេរើសចូល ។ ចេញពីគេមក ចេញពីគេមកបាន យកពីកងពលទៅបណ្តោយ

25- អ៊ាង : ពេលនោះ គឺថា ពេលដែលជួប ហ៊ីង ប៊ុនហៀងហ្នឹងថ្ងៃ២៦ អត់មាននិយាយរឿងអីទេ ?

26- ឆាយវី : អត់មាននិយាយរឿងអីទេ

27- អ៊ាង : ប៉ុន្តែគាត់មានសួរថាម៉េចទេ ?

28- ឆាយវី : គាត់មានសួរខ្ញុំថាមិនស្គាល់ ហ៊ីង ប៊ុនហៀងទេ ប៉ុន្តែពេលដែលគាត់និយាយ គាត់ទំនាក់ទំនងទំលាក់ពីរឿងហ្នឹងឯង

29- អ៊ាង : ប៉ុន្តែគាត់សួរថាម៉េច ?

30- ឆាយវី : គាត់សួរថា កាលដែលរៀនប៉ុន្មានខែ ខ្ញុំថាទៅរៀនប្រាំបីខែជាង ប៉ុន្តែគេដូចថា គេបំប៉នជាប់ប្រាំបួនខែហើយ ដល់ពេលខ្ញុំបកមកវិញហ្នឹង ខ្ញុំក៏មានការងារធ្វើធម្មតា ប៉ុន្តែថា ប្រាក់ខែវាគ្មានអញ្ចឹង បងណា ។ ហើយដល់ពេលខ្ញុំបកមកវិញនេះ ហើយក៏គាត់សិន កុំអាលទាន់និយាយរឿងហ្នឹង នៅជាមួយគាត់សិនទៅ ក្រែងលោមានប្រាក់ខែអីណាអញ្ចឹងទៅក្រែងវាធូរខ្លះ អញ្ចឹងទៅណាបងណាហើយបើកាលណា ខ្ញុំមានប្រាក់ខែ ខ្ញុំអាចសុំគេមកនៅជាមួយបងម្តងហើយក៏ផ្អាកប៉ុណ្ណឹង ទៅក៏សំរាកមួយសន្ទុះ ប្រហែលកន្លះម៉ោងបានបណ្តាញម្នាក់ទៀតមកនិយាយ ខ្ញុំមិនស្គាល់គេដែរ គេក៏និយាយពីនេះពីនោះ រឿងការងារហើយក៏មិនទាន់ទំលាក់ទៅលើកន្លែងនោះដែរ ។ ហើយដល់ពេលបាន...

31- អ៊ាង : ការងារហ្នឹងវាជាការងារធម្មតាទេ ហើយការងារបោកគ្រាប់បែកមិនទាន់និយាយទេ ?

32- ឆាយវី : បាទ ! ការងារធម្មតាទេ

33- អ៊ាង : ការងារលោកគ្រាប់បែកអត់ទាន់និយាយទេ ?
34- ឆាយរី : អត់ទាន់និយាយទេ ហើយដល់ពេលនោះទៅបានមួយសន្ទុះបានគេនិយាយ បានអានេះប្រាប់ ក៏នៅហ្នឹងដែរ នៅជាមួយគ្នាហ្នឹង ទាំងវាទាំងខ្ញុំ នៅជាមួយគ្នា ទើបនិយាយគ្នាលើឡាន ពីបញ្ហាលោកគ្រាប់បែក ។
35- អ៊ាង : និយាយលើឡាន និយាយថ្ងៃប៉ុន្មាន ?
36- ឆាយរី : ២៦ដដែលទេ
37- អ៊ាង : ២៦ពេលជួបគ្នាហើយហ្នឹង ហើយបាននិយាយគ្នាក្នុងឡាន ?
38- ឆាយរី : អាពេលជួបហ្នឹងនិយាយទំនាក់ទំនងគ្នា ប៉ុន្តែដូចថាមិនទាន់អញ្ចេះអញ្ចុះ ហើយដល់ពេលជិះឡាន...
39- អ៊ាង : ជិះឡានហ្នឹងថ្ងៃ២៦ដដែល ?
40- ឆាយរី : ថ្ងៃ២៦ដដែលហ្នឹង មកវិញ
41- អ៊ាង : ជិះឡានហ្នឹងគ្នាប៉ុន្មាននាក់ ?
42- ឆាយរី : ខ្ញុំ ពីរនាក់វា គាត់
43- អ៊ាង : លោក ហ៊ីង ប៊ុនហៀងផ្ទាល់ ហើយឈប់ ខ្ញុំចង់សួរបន្តិច ពេលដែលជួបហ៊ីង ប៊ុនហៀងនៅទួលក្រសាំងហ្នឹង ជួបនៅម៉ោងប៉ុន្មានដែរ ពេលដែលយើងគិតថ្ងៃត្រង់ហ្នឹង ?
44- ឆាយរី : អត់ទេ ! ជួបគ្នាពេលព្រឹក ប្រហែលម៉ោង ១០ហ្នឹង
45- អ៊ាង : ពេលនោះ ឆាយរីឯងជួបគ្នាម្នាក់ៗឬ ?
46- ឆាយរី : អត់ទេ ! ជួបទាំងអស់គ្នា
47- អ៊ាង : ធឿនឯងនៅហ្នឹងដែរ ?
48- ធឿន : បាទ !
49- អ៊ាង : តើអត់មាននិយាយការងារអីទេ ពេលជួបគ្នាចប់ហើយបានគាត់ជូនឡានមក ?
50- ឆាយរី : បាទ !
51- អ៊ាង : គាត់ជូនឡានមក គាត់សួរ គាត់សួរថាម៉េច ?
52- ឆាយរី : គាត់សួរ គាត់ថា ឥឡូវបើមិននេះទេធ្វើការជាមួយគេទៅ ហើយខ្ញុំសួរថាការងារអីបង ? ខ្ញុំរកការងារ ការងារប្រើតំរិះអោយឯងម្នាក់មួយម៉ឺនដុល្លារចាយ បើចង់ដឹងសួរពួកម៉ាកឯងទៅបានសួរលោកធឿននេះ បានអាធឿនគេរៀបរាប់ប្រាប់អញ្ចឹងៗទៅ ហើយក៏ជិះមកជាមួយគ្នាមក ក៏អោយលុយខ្ញុំមួយពាន់ ហើយខ្ញុំក៏ចុះនៅច្រមុះជ្រូក ខ្ញុំចុះហើយនៅពេលនោះ
53- អ៊ាង : ប៉ុន្តែមុនថ្ងៃទី២៦ មុនដែលពេលឆាយរីឯងទៅទួលក្រសាំងហ្នឹង ធឿនមាននិយាយប្រាប់ការងារអីខ្លះមុនទេ ?
54- ឆាយរី : មានប្រាប់ខ្លះដែរ
55- អ៊ាង : មានប្រាប់ថាម៉េច ?
56- ឆាយរី : ប្រាប់ថា បើមិននេះធ្វើការងារអង្គរក្សអីជាមួយគេសិនទៅណា ក្រែងលោបានលុយបានកាក់ ឥឡូវនេះគេកំពុងរកមនុស្ស
57- អ៊ាង : ប៉ុន្តែ អត់ដឹងថាមានផែនការអីទេ ?
58- ឆាយរី : អត់ដឹង ! ខ្ញុំក៏មិនដឹងថាមានអីដែរ គ្រាន់តែថាគេថាកំពុងរក មនុស្ស
59- អ៊ាង : ធឿន ដែលទៅជួបជាមួយឆាយរី មុនថ្ងៃ២៦ហ្នឹង មានជួបឆាយរីថ្ងៃប៉ុន្មានដែរ ធឿនឯងមានចាំទេ ? ជុំវិញការរកការងារធ្វើ ?
60- ធឿន : ក្នុងថ្ងៃ២៣ បង
61- អ៊ាង : ចុះលឺល្បីថា ហ៊ីង ប៊ុនហៀងទុកចិត្តធឿនឯង ពេលដែលនិយាយក្នុងឡានជាមួយឆាយរី ?
62- ឆាយរី : បាទ ! បាទ ! ទុកចិត្ត
63- អ៊ាង : ឥឡូវបន្ទាប់ពីមកដល់ច្រមុះជ្រូកហើយ ចុះពីឡានហើយពេលនោះតើឆាយរីឯងទៅណាទៀត ?
64- ឆាយរី : ខ្ញុំចុះពីរថយន្តហើយ ចូលបូលឌីញ
65- អ៊ាង : ចូលបូលឌីញ ?
66- ឆាយរី : ចូលបូលឌីញទៅរកទិញម៉ូតូនៅផ្សារថ្មី
67- អ៊ាង : ទិញម៉ូតូអស់ប៉ុន្មាន ?
68- ឆាយរី : ម៉ូតូអស់ ៨០០ សល់១០០អោយបងធឿន
69- អ៊ាង : រួចហើយបានម៉ូតូជិះដើរលេងទៅ រួចទៅកំបូលវិញទេ ?
70- ឆាយរី : ទៅ ! ទៅកំបូលល្ងាចហ្នឹង
71- អ៊ាង : រួចហើយគេណាត់ឲ្យមកនៅពេលណាដែរ ?
72- ឆាយរី : គេណាត់ឲ្យមកនៅថ្ងៃ៣០ មកពីព្រឹក
73- អ៊ាង : ចុះថ្ងៃ២៧-២៨ គេមិនណាត់ឲ្យមកទេ ?
74- ឆាយរី : អត់មានមកទេ ថ្ងៃ២៧-២៨
75- អ៊ាង : ថ្ងៃ៣០ មកពេលព្រឹក ?
76- ឆាយរី : បាទ ! មកពេលព្រឹក ប្រហែលម៉ោង ៤ភ្លឺ
77- អ៊ាង : មកទៅ គេអោយទៅជួបគេនៅឯណា ?
78- ឆាយរី : ជួបនៅក្រោយវត្ត
79- អ៊ាង : ពេលនោះ ឆាយរីឯងជិះអីទៅ ?
80- ឆាយរី : ខ្ញុំជិះម៉ូតូមក ខ្ញុំដាក់ម៉ូតូខ្ញុំនៅវត្តហ្នឹង ហើយរៀបចេញហ្នឹង បានជិះម៉ូតូឌុបទៅ
81- អ៊ាង : រៀបចេញ ?
82- ឆាយរី : បាទ ! ចេញទៅធ្វើបេសកកម្មគេនោះទៅណា
83- អ៊ាង : ឥឡូវពេលមកដល់វត្ត ពេលម៉ោង ៤ ឆាយរីឯង ពេលមកដល់ក្រោយវត្តហ្នឹងម៉ោងប៉ុន្មាន ?

84- ឆាយរី : ពេលមកដល់វត្តហ្នឹង ម៉ោងប្រហែល ៤ ខ្ញុំអាល័យហូបចុកតិចតួច បានមកដល់ម៉ោងប្រហែល ៥

85- អ៊ាង : ពេលចេញពីកំបូលមក ?

86- ឆាយរី : ម៉ោង ៤ ម៉ោង ៤ទៀបភ្លឺ

87- អ៊ាង : ហើយបន្ទាប់មក មកដល់វត្តប្រហែលម៉ោងប៉ុន្មាន ?

88- ឆាយរី : មកដល់ប្រហែល ម៉ោង ៤កន្លះ

89- អ៊ាង : ហើយមកដល់វត្តមានជួបពីណា ?

90- ឆាយរី : អត់មានជួបនរណា ឃើញតែមនុស្សពីរបីនាក់ ប៉ុន្តែមិនដឹងជាអ្នកណាទេ

91- អ៊ាង : ហើយគេស្លៀកពាក់របៀបម៉េចដែរ ?

92- ឆាយរី : មានស៊ីវិល មានទាហាន

93- អ៊ាង : មានស៊ីវិល មានទាហាន ហើយគេអត់មានសួរនាំឆាយរីឯងអីទេ ?

94- ឆាយរី : អត់មានទេ ខ្ញុំអង្គុយតែខ្ញុំ គេនៅតែគេ ខ្ញុំទៅណាក៏បានដែរ

95- អ៊ាង : ពេលធម្មតា ប្អូកហ្នឹងមិនងាយចូលងាយទេណា

96- ឆាយរី : បាទ !

97- អ៊ាង : ពេលឆាយរីឯងចូល ទំនាក់ទំនងម៉េចទើបបានចូល ?

98- ឆាយរី : ខ្ញុំទំនាក់ទំនង គេអោយខ្ញុំជួបគេនៅត្រង់ហ្នឹងបណ្តោយទៅ ខ្ញុំចូលបណ្តោយ

99- អ៊ាង : ព្រោះធម្មតាមានទាហាន ?

100- ឆាយរី : បាទ ! មានទាហាន ទាហានពេលទាហាននោះចូល គេអោយចូលបណ្តោយ គេអោយចូលតាមដំណើរ

101- អ៊ាង : អូ ! ចូលតាមដំណើរ ហើយគេអត់មានសួរនាំអីទេ ?

102- ឆាយរី : បាទ ! គេអត់មានសួរនាំអីទេ សួរនាំថាទៅណាអត់មានសួរទេ

103- អ៊ាង : គេឲ្យចូលតាមដំណើរ ចូលតាមច្រកណា ?

104- ឆាយរី : ចូលតាមក្រោយ មិនមែនចូលតាមនេះទេ ចូលពីក្រោយមកវិញ ចូលពីក្រោយវាំងមកវិញ

105- អ៊ាង : ចូលហ្នឹងគេឲ្យចូលធម្មតាទេ ?

106- ឆាយរី : បាទ !

107- អ៊ាង : ប៉ុន្តែកន្លែងហ្នឹង ឆាយរីឯង ដែលធ្លាប់ស្គាល់ ធ្លាប់ទៅមុនៗមក ធ្លាប់ចូលទៅទេ ?

108- ឆាយរី : កន្លែងហ្នឹងពីមុនៗមក ខ្ញុំធ្លាប់ដែលចូលដែរ ប៉ុន្តែមិនឃើញមានទាហានទេណា

109- អ៊ាង : កាលនោះ ចូលទៅលេងពីណា ?

110- ឆាយរី : ខ្ញុំអត់មានចូលទៅលេងជាមួយអ្នកណាទេ ខ្ញុំដើរតាមដំណើរ

111- អ៊ាង : ហើយ ចូលទៅអត់មានជួបពីណាទេ ?

112- ឆាយរី : ជួប ! មានមនុស្សហើយ

113- អ៊ាង : មានមនុស្សហើយ ?

114- ឆាយរី : បាទ ! មានមនុស្សហើយ

115- អ៊ាង : អត់ទាន់មានអ្នកណាមកនិយាយជាមួយឆាយរីឯងទេ ?

116- ឆាយរី : អត់ទាន់មានទេ គេនៅតែគេ ខ្ញុំនៅតែខ្ញុំ

117- អ៊ាង : អញ្ចឹង ! ពេលណាទៅ បានមានមនុស្សមកនិយាយជាមួយឆាយរីឯង ?

118- ឆាយរី : ប្រហែលជាម៉ោង ៧ ភ្លឺច្បាស់ហើយណា

119- អ៊ាង : អញ្ចឹង ! ឆាយរីឯង ចាំយូរទេ ?

120- ឆាយរី : ខ្ញុំចាំយូរហើយ ខ្ញុំមកតាំងពីយប់ម្ល៉េះ មកម៉ោង ៤កន្លះ គឺខ្ញុំទៅហូបអីនៅក្រៅអញ្ចឹងណា ប៉ុន្តែពេលខ្ញុំប្រហែលជាម៉ោង ៧ ទៅដល់ដើរចុះដើរឡើងៗ ក៏បានជួបជុំគ្នាហ្នឹង ប៉ុន្តែមិនដឹងជានរណាជានរណាទេ អត់ស្គាល់ទេ

121- អ៊ាង : ហើយយើងមានចាប់អារម្មណ៍អីទេ ?

122- ឆាយរី : អត់ចាប់អារម្មណ៍ទេ ហើយមិនទាន់ដឹងថា ថ្ងៃហ្នឹងគេឲ្យខ្ញុំធ្វើឬក៏អត់ទេ ខ្ញុំមិនទាន់ដឹងទេ គេអោយខ្ញុំជួប មិនដឹងជួបរឿងស្អីទេ

123- អ៊ាង : នៅពេលម៉ោងប៉ុន្មានគេមកជួបឆាយរីឯង ?

124- ឆាយរី : ប្រហែលជាម៉ោង ៨

125- អ៊ាង : ប្រហែលម៉ោង ៨ៗ ពីណាមកជួបឆាយរីឯង ?

126- ឆាយរី : ជួបជុំក្រុមហ្នឹងទាំងអស់

127- អ៊ាង : ក្រុម ?

128- ឆាយរី : បាទ ! ប៉ុន្តែ មិនដឹងជានរណា ប៉ុន្តែឃើញមួយហ្វូងទៀតនៅក្រៅ មានតាំងពីទាហាន មានតាំងពីម្ហូកសំណាញ់ស្អីទាំងអស់

129- អ៊ាង : ប៉ុន្តែមនុស្សដែលមកជួបនិយាយជាមួយឆាយរីឯងមាននរណាគេមកជាមួយទេ ?

130- ឆាយរី : មនុស្សមានម្នាក់ មានមាឌធំមកនិយាយជាមួយខ្ញុំហ្នឹង

131- អ៊ាង : គេនិយាយថាម៉េចទៅ ?

132- ឆាយរី : គេ គាត់និយាយថា ខ្ញុំក៏មិនដែលមកជួបដែរគាត់មកដល់កន្លែង គាត់ថាមកហើយ ! បាទ ! ខ្ញុំមកហើយ ហើយឯណាបងទៅណា ? ខ្ញុំក៏សួរអ្នកណា ? គាត់ថាឃើញធឿនទេ ? ខ្ញុំថាមិនទាន់ឃើញមកទេ...

133- អ៊ាង : ចុះបន្ទាប់មកទៀត ?

134- ឆាយវី : បន្ទាប់មកទៀតបានពេលរៀបចេញធ្វើការហ្នឹង ឃើញមកជុំគ្នា ប៉ុន្តែមិនដឹងជានរណាខ្ញុំស្មានថាទាហានគេធ្វើការនៅហ្នឹងអីហ្នឹង បានគេប្រាប់ទៅខ្ញុំថា បើការហើយចាំអាហ្នឹង ខ្ញុំនិយាយរឿងបោកហើយ ប៉ុន្តែពេលខ្ញុំចេញមក ហ៊ីង ប៊ុនហៀង បានមកជួបខ្ញុំ ក៏មិនជួបស្អីដែរ គ្រាន់តែហុចគ្រាប់អោយខ្ញុំមួយគ្រាប់ គឺគ្រាប់បែក

135- អ៊ាង : គ្រាប់បែកហ្នឹងម៉ាកអីគេ ?

136- ឆាយវី : ម៉ាករបស់ចិន អាតូចប៉ុណ្ណេះ បានគេថា បើបែកបានលុយ បើមិនបែកមិនបានលុយទេ ហើយគាត់ដើរហួសទៅ ខ្ញុំក៏មិនចំណាំមុខគាត់ហើយគាត់ក៏មិនចំណាំមុខខ្ញុំដែរ

137- អ៊ាង : រួចហើយបានអ្នកណានាំឆាយវីឯងចេញ ?

138- ឆាយវី : អ្នកនាំខ្ញុំ គឺម្នាក់ដែលមាឌធំដែលខ្ញុំជួបដំបូង ដែលថាមកហើយហ្នឹងហើយនោះ ម្នាក់ហ្នឹង

139- អ៊ាង : ប៉ុន្តែ នៅក្នុងចំណោមមនុស្សដែលថាក្រុមផ្សេងៗហ្នឹង មានឃើញវត្តមានប្រេស៊ីលទេ ?

140- ឆាយវី : ក្នុងចំណោមនេះ ខ្ញុំក្រឡេកឃើញភ្លែត ហ្នឹងហើយដែលខ្ញុំចំណាំ ដូចថារៀបគប់ទីមួយ...

141- អ៊ាង : ប៉ុន្តែ នៅក្រោយវត្តបទុមហ្នឹង កាលដែលមុនមកធ្វើការងារហ្នឹង ឃើញនៅក្នុងចំណោមនេះដែរ ?

142- ឆាយវី : បាទ ! ឃើញ ឃើញនៅក្នុងចំណោមនោះដែរ សង្កេតមនុស្សដូចជាមិនល្អសោះ ចំណាំពេលខ្ញុំទៅណាក៏ដោយក៏ខ្ញុំចំណាំគាត់ដែរ ហើយដល់ពេលខ្ញុំចេញរឹបបាត់វា

143- អ៊ាង : ហើយមនុស្សមាឌធំហ្នឹង ?

144- ឆាយវី : បានម្នាក់មាឌធំដែលពាក់មួកនោះអ្នកនាំខ្ញុំចេញ បាទ ! ហើយមករកម៉ូតូឌុបនៅនោះ ពីរបីគ្រឿង គេអោយខ្ញុំជិះម៉ូតូឌុបទៅខ្ញុំចុះនៅក្រោមដើមមៀន បាទ ! ហើយពេលហ្នឹងគេចាប់ផ្តើមហើយក្រុមបាតុកម្មបានមកដល់ហើយ ហើយពេលមកដល់វាជិះឆេវឆាប

145- អ៊ាង : ឆាយវីឯងជិះតែម្នាក់ឯងគត់ទេម៉ូតូហ្នឹង ?

146- ឆាយវី : ខ្ញុំជិះម៉ូតូឌុប

147- អ៊ាង : ជិះម៉ូតូឌុបហ្នឹងជិះតែម្នាក់ឯងគត់ ?

148- ឆាយវី : បាទ ! ម្នាក់ឯង

149- អ៊ាង : ហើយម៉ូតូឌុបហ្នឹងឈប់អោយឆាយវីឯង ឬក៏ឆាយវីឯងកុំម៉្ញង់ ?

150- ឆាយវី : អត់ទេ ! ម៉ូតូឌុបគេឈប់ ហើយឲ្យឈរនៅកន្លែងហ្នឹង

151- អ៊ាង : អញ្ចឹង! បានន័យថាមនុស្សហ្នឹងមិនមែនអ្នកម៉ូតូឌុបទេ ?

152- ឆាយវី : ខ្ញុំក៏សង្ស័យអញ្ចឹងដែរ ថាម៉ូតូឌុប គេថាអោយឈប់ត្រង់ណា គឺឈប់ត្រង់ហ្នឹង ហើយពេលខ្ញុំឈរមិនទំនងក៏ឆ្លងកាត់ហើយខ្ញុំក៏ដើរទៅក្រោមដើមអំពិល ស្រាប់តែខ្ញុំងាកមកវិញ ឃើញអាប្រេស៊ីលវាគប់ ហើយមិនដឹងវាគេចទៅណាទេ ហើយក៏ប៉ុន្មាននាក់ចេញពីណាមកណាគប់ ត្រង់ថាវាចេញពីណាមកណាខ្ញុំក៏មិនបានដឹងទេ រឿងគ្រាប់ដែលផ្ទុះហ្នឹងមិនដឹងចេញពីណាទេ ខ្ញុំអត់បានដឹងទេ អាប្រេស៊ីល គេគប់ទៅ

153- អ៊ាង : អាប្រេស៊ីលច្បាស់ជាងគេ ?

154- ឆាយវី : បាទ ! ច្បាស់ជាងគេ អាប្រេស៊ីល គ្រាន់តែងាកខ្លួនទៅ ខ្ញុំក៏ចាប់ផ្តើមទៅខាងសួនច្បារនោះទៅវិញ រួចរត់ចូលវត្តបទុម ទៅពីវត្តបទុមហ្នឹងទៅមានទាហានគេយាម មានមួកសំណាញ់ខ្ញុំរត់ទៅ មានគេរត់តាមពីក្រោយ ខ្ញុំក៏ចូលវត្ត ចូលក្នុងវត្តមានឃើញទាហាននៅក្នុងវត្ត ។

155- អ៊ាង : ពេលឆាយវីឯងបោក បោកគ្រាប់ទីប៉ុន្មាន ?

156- ឆាយវី : ខ្ញុំគ្រាប់ទី ៤

157- អ៊ាង : រួចហើយ បោកភ្លាម រត់ ?

158- ឆាយវី : បាទ ! រត់បណ្តោយ

159- អ៊ាង : ហើយចូលវត្តមុនគេ ?

160- ឆាយវី : ខ្ញុំចូលវត្តមុនគេ ហើយក្រុមរបស់គេមិនដឹងរត់ទៅណាៗ ខ្ញុំមិនដឹង ឬក៏គេចូលចន្លោះឯណាក៏មិនដឹងដែរណា ប៉ុន្តែខ្ញុំរត់មុនគេ...

161- អ៊ាង : រត់ ! រត់កាត់វត្តតែម្តង ?

162- ឆាយវី : អត់ទេ ! រាងបញ្ឆិត បញ្ឆិតវត្ត មានទាហានគេយាមហ្នឹង ខ្ញុំក៏...

163- អ៊ាង : ចូលតាមប្រឡោះណា ?

164- ឆាយវី : ចូលចំហៀងវត្តទៅវិញ

165- អ៊ាង : ចំហៀងវត្ត ផ្លូវ ? អត់បានចូលកាត់តាមវត្តទេ ?

166- ឆាយវី : អត់ទេ ! ដូចគប់ត្រង់នេះ ខ្ញុំចូលបញ្ឆិតវត្ត

167- អ៊ាង : គូសប្លង់សិន នេះផ្លូវមុខវត្ត នេះវត្ត ហើយទាហានគេរាយរហូត ហើយបន្ទាប់មក មិនចប់ខ្សែត្រៀមទាហាន ទាហានរាយកាត់មុខវត្ត

168- ឆាយវី : ហ្នឹង ! កាត់វត្ត ផ្លូវច្រកវត្តហ្នឹង

169- អ៊ាង : ចុះវត្ត ! ចេញតាមផ្លូវណា ? វត្តមានរបង

170- ឆាយវី : បាទ ! មានរបង

171- អ៊ាង : ចេញទ្វារវត្ត ចេញទ្វារមួយណា ?

172- ឆាយវី : ទ្វារក្រោយវិញ

173- អ៊ាង : ទ្វារក្រោយ ?

174- ឆាយវី : បាទ !

175- អ៊ាង : មានផ្លូវមួយ រួចបានចូលក្នុងផ្លូវមានឃើញមនុស្សប៉ុន្មាននាក់ ?

176- ឆាយវី : មានឃើញតែទាហាន អត់មានឃើញប្រជាជនទេ

177- អ៊ាង : ទាហានប្រហែលប៉ុន្មាននាក់ ?

178- ឆាយវី : ទាហានមានប្រហែល...ច្រើនដែរតើ ប្រហែលម្ភៃសាម ម្ភៃនាក់អីអញ្ចឹង ខ្ញុំមិនបានរាប់ដែរ

179- អ៊ាង : ប៉ុន្តែ ទាហានក៏អត់មានសួរនាំឆាយវីឯងថា មកពីណាមកពីណីអី ?

180- ឆាយវី : អត់មានសួរទេ ប៉ុន្តែដូចថា ជួយគេចាប់ផ្ដើមជួបសង្គ្រាម ដូចថារត់ចុះឡើងៗ ដូចខ្ញុំដែរ រត់ចុះឡើងៗ ដូចខ្ញុំដែរ បាទ ! គេដឹងថា ខ្ញុំហ្នឹងស៊ីវិលដែរទេ...

181- អ៊ាង : ហើយគេអត់មានសួរនាំអីទេ ?

182- ឆាយវី : អត់មានសួរនាំអីទេ

183- អ៊ាង : ហើយពេលណាទៅបានឆាយវីឯងចេញពីកន្លែងហ្នឹង ?

184- ឆាយវី : ខ្ញុំនៅប្រហែលជាប្រាំនាទី ខ្ញុំមើលឃើញសភាពការណ៍ ដូចជាមិនស្រួល នៅក្នុងចំណោមទាហានប៉ុន្មាននាក់ហ្នឹង ខ្ញុំមើលមុខដឹង ក៏រត់ចេញទៅ

185- អ៊ាង : ហើយឆាយវីឯងមានលាពួកហ្នឹងទេ ?

186- ឆាយវី : អត់មានលាគេទេ គេក៏មិនបានសួរខ្ញុំដែរ ខ្ញុំក៏មិនសួរគេដែរ

187- អ៊ាង : ហើយនៅពេលហ្នឹង នៅពេលដែលឆាយវីឯងបើទទួលលុយបានមួយពាន់ដុល្លារហ្នឹង តើមានទឹកចង់បានលុយប្រាំបួនពាន់ដុល្លារ មកបង្គ្រប់ទៀតទេ ?

188- ឆាយវី : ចិត្តគឺចង់ដែរបង ចិត្តរឿងលុយចង់ ប៉ុន្តែមើលទៅសភាព គឺវាមិនស្រួល ខ្ញុំក៏មិនចង់បានដែរ

189- អ៊ាង : លែងចង់បាន ?

190- ឆាយវី : បាទ ! លែងចង់បាន

191- អ៊ាង : ហើយក៏ជិះម៉ូតូចេញទៅ ?

192- ឆាយវី : បាទ ! ជិះម៉ូតូចេញទៅ

193- អ៊ាង : ជិះម៉ូតូចេញហើយទៅណាទៀត ?

194- ឆាយវី : ខ្ញុំឡើងទៅកំបូល បាទ ! ហើយខ្ញុំចេញពីកំបូលមកក្នុងក្រុង

195- អ៊ាង : ទៅកំបូល ទៅកំបូលថ្ងៃប៉ុន្មាន ?

196- ឆាយវី : ទៅក្នុងថ្ងៃហ្នឹងហើយបង

197- អ៊ាង : ទៅកំបូល ?

198- ឆាយវី : ខ្ញុំក៏ទៅយកខោអាវក៏ចេញមក

199- អ៊ាង : អត់មាននៅកំបូលទៀតទេ ?

200- ឆាយវី : អត់មាននៅទេ រហូតតាំងពីពេលហ្នឹងមក

201- អ៊ាង : ចេញពីកំបូលមានទៅណាទៀត ?

202- ឆាយវី : ខ្ញុំចេញពីកំបូល ខ្ញុំមកនៅបឹងកក់ ប្រហែលមួយយប់ពីរយប់ បានខ្ញុំចេញពីហ្នឹងទៅកំពង់ចាម

203- អ៊ាង : នៅបឹងកក់នៅជាមួយពីណា ?

204- ឆាយវី : ខ្ញុំនៅផ្ទះជួល

205- អ៊ាង : នៅផ្ទះជួល មានប្រពន្ធកូនអីទេ ?

206- ឆាយវី : អត់មាននៅទេ...

207- អ៊ាង : រួចហើយ បានចេញពីបឹងកក់ទៅណា ?

208- ឆាយវី : ខ្ញុំទៅកំពង់ចាមបណ្ដោយ

209- អ៊ាង : ចុះម៉ូតូលក់នៅឯណា ?

210- ឆាយវី : លក់នៅកំពង់ចាម

211- អ៊ាង : លក់អោយអ្នករកស៊ី ?

212- ឆាយវី : លក់អោយអ្នករកស៊ី

213- អ៊ាង : ចេញពីកំពង់ចាមទៅនៅឯណា ?

214- ឆាយវី : ខ្ញុំទៅដល់ក្រចេះ

215- អ៊ាង : ទៅដល់ក្រចេះផ្ទះពីណា ?

216- ឆាយវី : ផ្ទះប្អូន

217- អ៊ាង : ថ្ងៃដែលឆាយវីបោកគ្រាប់បែកហ្នឹង ថ្ងៃហ្នឹងឆាយវីឯងស្លៀកពាក់ខោអាវអី ?

218- ឆាយវី : ខ្ញុំស៊ីវិល

219- អ៊ាង : ស៊ីវិល !

220- ឆាយវី : អាវដៃវែង និងអាវយឺតក្នុង នេះ អាវពណ៌ហ្នឹង ប៉ុន្តែអាវដៃវែង ពណ៌ហ្នឹង

221- អ៊ាង: ពណ៌ហ្នឹង ! ពណ៌ដូចគ្នាហ្នឹង ?

222- ឆាយវី : ពណ៌ដូចគ្នាហ្នឹង ប៉ុន្តែពាក់អាវយឺតក្នុង

223- អ៊ាង : រួចចុះគ្រាប់បែក គ្រាប់បែកសៀតយ៉ាងម៉េច ?

224- ឆាយវី : ខ្ញុំដាក់នៅចង្កេះ

225- អ៊ាង : អាគ្រាប់បែកចិនប៉ុណ្ណា ?

226- ឆាយវី : តូច

227- អ៊ាង : ពេលដែលឆាយវីឯងចេញទៅបោកបែបហ្នឹង មានមនុស្សគេតាមទេ ?

228- ឆាយវី : មាន មានគេតាម ប៉ុន្តែមិនដឹងថា ឬមួយគេដើរតាមជាមួយខ្ញុំ ឬមួយគេទៅណា ប៉ុន្តែផ្លូវដែលខ្ញុំទៅណា គេទៅហ្នឹងដែរ ប៉ុន្តែមិនមែនថាទៅនេះទៅនោះ ប៉ុន្តែខ្ញុំឆ្លងមក គេឆ្លងមកដែរ ប៉ុន្តែពេលឆ្លងបាត់គេ ខ្ញុំនៅក្រោមដើមអំពិល

229- អ៊ាង :  ហើយអ្នកបោកគ្រាប់ទីពីរទីបីហ្នឹង ឆាយវីឯងអត់ដឹងថាចេញពីកន្លែងណាកន្លែងណាទេ ?

230- ឆាយវី  :  អត់ដឹងទេ !  ប៉ុន្តែអាមួយលើ  អានេះហ្នឹងគឺចេញពីរបងអែបសភាមក

231- អ៊ាង  :  អាហ្នឹងគ្រាប់ទីមួយ ?

232- ឆាយវី  :  បាទ  !

233- អ៊ាង  :  បានឃើញអាប្រេស៊ីលហ្នឹង ?

234-  ឆាយវី : បាទ  !  បានឃើញប្រេស៊ីលហ្នឹងតែម្តង  ។ ខ្ញុំមិនស្គាល់ឈ្មោះប្រេស៊ីលហ្នឹងផង ប៉ុន្តែចំណាំមុខ ក្នុងចំណោមទៅហ្នឹង    ឃើញអានោះមួយ  ប៉ុន្តែបើតាមខ្ញុំមើលទៅ ដូចជាអាក្រក់

235- អ៊ាង  :  គ្រាន់តែឃើញ  បានសំគាល់ជាងគេ  អញ្ចឹងទៅ ?

236-  ឆាយវី : បាទ ! ខ្ញុំក៏មើលទៅ ងាកទៅឃើញវា  ដឹងថាអាហ្នឹងឯង  ដល់មានរឿងទៅខ្ញុំក៏ចាប់ផ្តើម...

237- អ៊ាង :  ហើយទើបតែមុនចេញ  អាព្រឹកថ្ងៃមុនចេញពីវត្តបទុមពេលដែល  ហ៊ីង  ប៊ុនហៀងហុចគ្រាប់បែកអោយ  តើហ៊ីង  ប៊ុនហៀងផ្តាំថាម៉េច ?

238-  ឆាយវី : ផ្តាំថា   ទាល់តែបែកបានអោយលុយ   បើមិនបែកទេអត់បានលុយទេ

239-  អ៊ាង  :  ហើយពេលនោះ  ឆាយវីឯងមានចាំទេ  ពេលដែលគាត់ជួបឆាយវីឯង ហុចគ្រាប់បែកអោយហើយ  គាត់បានដើរទៅណាទៀត ?

240-  ឆាយវី : គាត់ដើរ ខ្ញុំក៏ចេញទៅ ប៉ុន្តែមិនបានសំណេះសំណាលឬមួយសួរខ្ញុំពីអ្វីមួយនោះ  ក៏មិនបានសួរដែរ  ព្រោះថាគ្រាប់បែកបែកបានបានលុយ  មិនបែកមិនបានលុយទេ  ធ្វើម៉េចម៉ារួចខ្លួន  កំណត់ម៉ារួចខ្លួន...

241- អ៊ាង  :  ហើយតើសង្កេតឃើញគាត់ដើរទៅជួបអ្នកណា ?

242- ឆាយវី  :  អត់ជួបនរណាទេ

243- អ៊ាង  :  គឺដើរទៅបាត់ !

244-  ឆាយវី :   បាទ !  ព្រោះពួកគេមានក្រុមរបស់គេ  ព្រោះខ្ញុំមិនមែននៅក្នុងក្រុមជាមួយគេ   គេខ្លាចខ្ញុំ  ខ្ញុំក៏មិនដឹងរឿងគេដែរ គ្រាន់ថា ពេលទៅណាមកណា  គ្រាន់តែចាំមើល...

245- អ៊ាង  : អញ្ចឹង ពេលហ្នឹង គេអត់មានបញ្ហាថា អោយឆាយវីឯងបោកគ្រាប់ទីប៉ុន្មាន ?

246- ឆាយវី  :  ទេ  អត់មានទេ  អត់មានបញ្ហាទីប៉ុន្មានទេ

247- អ៊ាង  :  បានន័យថា  ឆាយវីឯងឮគេបោកឌឹងៗ  ?

248-  ឆាយវី :  ឌឹងៗ រាងចន្លោះវែងបានខ្ញុំដាក់  មិនមែនឌឹងៗនោះទេ  វារាងដូចឃ្លាត

249- អ៊ាង :  ឥឡូវ ! ខ្ញុំចង់ដឹងថា  សំឡេងគ្រាប់ឮយ៉ាងម៉េច  ពេលដែលគេ...

250- ឆាយវី : ឮឌឹងៗ  ទើបខ្ញុំបន្តមួយដង្ហើម  មិនមែនថាមួយដង្ហើមមួយឃ្លាត

251- អ៊ាង  :  មានគ្រាប់ទីបីទីបី  ចាំមើលណា  មានគ្រាប់ទីមួយទីពីរទីបីឮយ៉ាងម៉េចដែរ ?

252-  ឆាយវី  :  ពេលនោះខ្ញុំអត់បានផ្ទៀង  ខ្ញុំអត់បានផ្ទៀង  ព្រោះកន្លែងនោះ  កំពុងតែជ្រួលច្របល់

253- អ៊ាង : ពេលដែលឆាយវីឯងទៅដល់កន្លែងបាតុកម្ម  ពេលនោះតើពីណានៅកំពុងនិយាយ ?

254- ឆាយវី : ពេលកំពុងបាតុកម្ម  ខ្ញុំឃើញលោកប្រធានកំពុងតែដៃជើងច្រងេងច្រងាង គាត់កំពុងនិយាយពីបញ្ហាអ្វី ខ្ញុំអត់ដឹងដែរ  ខ្ញុំនៅឆ្ងាយ

255- អ៊ាង  :  កាន់ម៉េក្រូ ?

256- ឆាយវី  :  បាទ !

257- អ៊ាង :  អញ្ចឹងពេលដែលផ្ទុះគ្រាប់បែក  ពីណាអ្នកនិយាយ ?

258-  ឆាយវី  :  ពេលគប់គ្រាប់បែកខ្ញុំមិនដឹងទេ  ខ្ញុំមិនបានមើលនរណាទាំងអស់

259- អ៊ាង  :  គ្រាន់តែចាំ  សំរាប់ធ្វើការងារហ្នឹងឯង ?

260- ឆាយវី  :  បាទ  !  ធ្វើការងារ  សំរាប់តែលុយតែប៉ុណ្ណឹង

261- អ៊ាង  :  ហើយ ! តើពីណាអ្នកណាត់អោយឆាយវីឯង មក...?

262- ឆាយវី : គេអ្នកណាត់នោះ  គឺ  ពេលនោះ  ស្អី  គាត់ឈ្មោះអីហ៊ីង  ប៊ុនហៀង

263- អ៊ាង  :  ណាត់ពេលណា ?

264- ឆាយវី  :  ណាត់ពេលក្នុងឡាន

265- អ៊ាង  :  ពេលក្នុងឡាន ?

266-  ឆាយវី  : បាទ ! ហើយគាត់ក៏មិនបានប្រាប់ ធឿនគេប្រាប់ខ្ញុំតែខ្ញុំមិនចាប់ភ្លឹកកន្លែងណាៗ  ក៏ខ្ញុំអត់ដឹងដែរ   ទាល់តែសួរលោកធឿនទើបបានដឹង  បាទ  !

267- អ៊ាង : ប៉ុន្តែ  នៅមុខវត្តបទុមគេអត់ប្រាប់ថាចូលយ៉ាងម៉េចទេ ?

268- ឆាយវី  :  ...

269- អ៊ាង  :  អូ  !  កន្លែងផ្លូវភ្លោះហ្នឹង ?

270-  ឆាយវី  :  បាទ  !   នៅត្រង់ហ្នឹងនៅឃើញទាហានអីនៅយាមឈប់ត្រង់ហ្នឹងទៅ  ។

271-  អ៊ាង : ហើយ  ដល់ពេលហើយ  ក៏គេចបាត់ទៅលក់ម៉ូតូបានថ្លៃប៉ុន្មាន ?

272- ឆាយរី : ជិតប្រាំបីរយ ខ្ញុំបានលក់បានប្រាំពីររយប៉ែត លក់នៅកំពង់ចាម

273- អ៊ាង : តាំងពីមកពីឥណ្ឌូនេស៊ីវិញមុនមួយខែមុនគប់គ្រាប់បែក ឆាយរីឯងចូលលេងទួលក្រសាំងបានប៉ុន្មានដង ?

274- ឆាយរី : ខ្ញុំបានទៅតែម្តងទេ

275- អ៊ាង : ម្តងហ្នឹង ?

276- ឆាយរី : ទៅលេងម្តង ទៅផ្លូវការហ្នឹងម្តង ឡើងពីរដង ទៅម្តងហ្នឹងទៅអត់ជួបវានេះទេ បានទៅពេលក្រោយគេនិយាយ ពីរឿងខ្ញុំអញ្ចេះអញ្ចុះទៅ វាចាប់ភ្លឹក ទៅថ្ងៃក្រោយលេងជាមួយវាហ្នឹង ជួបវាហ្នឹង អញ្ចឹងបានក្រុមពួកគេហ្នឹង គេថាអោយខ្ញុំទៅនៅជាមួយគេ អញ្ចឹងអញ្ចេះអញ្ចុះ ក៏ចាប់ផ្តើមពីពេលនោះឯង ។

277- អ៊ាង : ចំណែកធឿនស្គាល់ឆាយរីពីពេលណា ធឿន ?

278- ធឿន : ស្គាល់យូរហើយ មួយឆ្នាំពីរឆ្នាំហើយ តាំងពីមកពីឥណ្ឌូនេស៊ី

279- អ៊ាង : ស្គាល់គ្នា ?

280- ធឿន : បាទ !

281- អ៊ាង : ស្គាល់គ្នាធ្លាប់ស៊ីផឹកជាមួយគ្នា ?

282- ធឿន : បាទ ! ធ្លាប់ស៊ីផឹកដេកនៅជាមួយគ្នាហ្នឹង ចេញចូលផ្ទះសំបែងអី

283- អ៊ាង : ប៉ុន្តែធឿនឯងស្គាល់ប្រេស៊ីលច្បាស់ទេ ?

284- ធឿន : ច្បាស់បង !

285- អ៊ាង : ស្គាល់ច្បាស់ ?

286- ធឿន : បាទ !

287- អ៊ាង : ហើយធ្លាប់និយាយអីគ្នាទេ ?

288- ធឿន : ធ្លាប់ ! ហើយចេញចូលចេញចូលហ្នឹង

289- អ៊ាង : ហើយស្គាល់ផ្ទះ ?

290- ធឿន : ស្គាល់ផ្ទះទៀត

291- អ៊ាង : ហើយស្គាល់មុខម្តាយទេ ? ស្គាល់មុខឪពុកម្តាយប្រេស៊ីលទេ ?

292- ធឿន : អត់ស្គាល់ទេ តែផ្ទះស្គាល់

293- អ៊ាង : ស្គាល់ ! ហើយខ្ញុំឆ្ងលចឆ្ងល់ ធឿនឯងនឹកឃើញយ៉ាងម៉េចបាន យកព័ត៌មានរឿងឆាយរីបោកគ្រាប់បែកមកប្រាប់គាត់ ?

294- ធឿន : ខ្ញុំមិនដឹងនឹកឃើញយ៉ាងម្តេចមុនដំបូង ពេលដំបូងហ្នឹង អាពេលកើតហេតុហើយ កើតហេតុហើយហ្នឹង ខ្ញុំឮកាសែតនិយាយអញ្ចេះអញ្ចុះថា ទំលាក់កំហុសមកលើឯកឧត្តម សម រង្ស៊ី ហើយខ្ញុំនេះចេះតែអង្គុយអស់សំណើច តែរយះពេលហ្នឹង ខ្ញុំដឹងរឿងគេច្បាស់ណាស់បង ដល់ខ្ញុំដឹង ដឹងរឿងគេច្បាស់ខ្ញុំចេះតែពិចារណាថ្ងឹងថ្ងែង ដល់ថ្ងឹងថ្ងែងហើយ ក្រោយមកទៀត ក្រោយមកដឹងបាត់អាពួកនេះ ដល់បាត់ពួកនេះ ខ្ញុំចេះតែរកមើលវាមិនដឹងជាទៅ ណាមកណារកមិនឃើញ ស្អីមិនឃើញ ខ្ញុំក៏ទៅផ្ទះអាប្រេស៊ីល ដល់តែទៅសួរ សួរថាឯងឃើញអាមួយប្រជ្រុយដែលជួបវាដែរទេ ? វាថាអត់ដែលជួបទេ ខ្ញុំសួរថា ចុះពួកហ្អែងប៉ុន្មាននាក់ ហ្នឹងទៅណាអស់ហើយ វាថា ទៅអស់ហើយបងអើយ ទៅណាអស់ ? វាថាគេ យកទៅកំពង់សោមអស់ហើយ អាហ្នឹងឈប់និយាយឮហើយ បានហៅវាមកសួរ គ្រាន់តែហើយអីចឹងហើយ ខ្ទង់ម៉ោង ១១ វាដឹកខ្ញុំចេញពីផ្ទះនោះទៅ ទៅដល់ទួលក្រសាំង គេដឹកយន្តហោះទៅកំពង់សោម

295- អ៊ាង : ចុះពួកហ៊ីង ប៊ុនហៀង អត់ស្គាល់ផ្ទះប្រេស៊ីលទេ ?

296- ធឿន : បាទ ! ស្គាល់

297- អ៊ាង : ចុះពេលដែលប្រេស៊ីលរត់ ម៉េចមិនតាមរកដល់ផ្ទះ ?

298- ធឿន : ពេលដែលរត់ វានៅឯណោះ ទាំងអស់គ្នាទៅកំពង់សោម ដល់ពេលរត់មក ខ្ញុំទៅសួរហ្នឹងក៏នេះដែរស្ងាត់ៗដែរ ទៅដល់វាមិនចង់ជួបខ្ញុំទេ អ្នកផ្ទះគេចេះលាក់អញ្ចេះអញ្ចុះ ដល់ខ្ញុំទៅសួរ ទៅដល់ស្រាប់តែទៅវាក់អើ វាក់អើវាប្រុងគេចខ្ញុំ ដល់ប្រុងគេចខ្ញុំ ខ្ញុំថាឯងមកនេះ សួរបន្តិច វាក៏ចេញមកជួប ខ្ញុំក៏សួរ សួរតាមដំណើរមិញហ្នឹង សួររកវាហ្នឹងថាកាលទៅៗ៦នាក់ទេ ? អាម្នាក់ហ្នឹងអត់ឃើញទេបង បាត់តាំងពីថ្ងៃកើតហេតុហ្នឹងរហូត ដល់រួចខ្ញុំថា បើអញ្ចឹងហ្អែងម៉េចមិនគេចខ្លួនទៅ ឯងមកនៅផ្ទះធ្វើអ្វី ? វាថាខ្ញុំកំពុងតែគិតបន្តិចទៀតខ្ញុំនឹង សុំគេធ្វើទាហានធ្វើអី ខ្ញុំថាបើធ្វើទាហានធ្វើទៅម៉េចៗការពារ ខ្លួនអោយរស់សិនរើយ ហើយចាំបន្តិចទៀតមើល វាយ៉ាងម៉េច ផុតពីហ្នឹងខ្ញុំក៏ទៅផ្ទះ ទៅផ្ទះឮប្រពន្ធខ្ញុំថាអ្នកធ្វើការជាមួយមករកខ្ញុំ រកមានការអី ? គេថាអត់ដឹង មកពីរបីនាក់ជិះម៉ូតូ ហើយបើបងឯងមកអោយទៅកន្លែងធ្វើការ ។ ខ្ញុំថាអត់ស្រួលទេ មិនបានធ្វើតែដឹងរឿង ហើយអាគេធ្វើគេយកទៅអស់ហើយៗ តែទៅប្រាកដជាងាប់ហើយ ។ ខ្ញុំអត់មាត់រួចខ្ញុំក៏ចេញពីផ្ទះ ខ្ញុំប្រាប់ប្រពន្ធខ្ញុំថាបើអ្នកណាមករកអញ ថាអត់ដឹងទៅណាទេ បើគេសួរថាលែងគ្នាហើយ មិនដឹងទៅណាទេ ខ្ញុំប្រាប់ប្រពន្ធខ្ញុំអញ្ចឹង ខ្ញុំគេចរហូត ខ្ញុំទៅនៅកំពង់ចាមរកស៊ីដឹកឈើដឹកអី ជញ្ជូនឈើជញ្ជូនអីអោយគេបានប៉ុន្មានជើង ខ្ញុំធ្វើបានពីរជើង ទៅរកអានេះ ខ្ញុំទៅរកអានេះ ដល់ទៅរកអានេះ គិតថាផ្លូវទឹក អញរកស៊ីឈើចូលកំពង់ចាមប្រាកដជាគេស្គាល់ខ្ញុំ គេស្គាល់ខ្ញុំច្បាស់ណាស់កំពង់ចាម ដល់ខ្ញុំថាអាហ្នឹងរឹតតែបញ្ចេញមុខទៀតហើយ ! ខ្ញុំក៏ឈប់ ដល់ឈប់ ខ្ញុំមកនៅជាមួយប្រពន្ធចុងនៅកំពង់ចាមហ្នឹង នៅឆ្ងាយណាស់នៅព្រៃឈរជាប់ព្រំប្រទល់កងមាស នៅជាមួយប្រពន្ធខ្ញុំ រកត្រីរកអីហ្នឹងជាមួយគេហ្នឹង

ទៅ ដាក់មងដាក់អី នៅផ្ទះហ្នឹងបាយផ្លូកអីនៅផ្ទះហ្នឹង រហូតដល់ក្រោយមក បានខ្ញុំមកផ្ទះ មកផ្ទះហ្នឹង បានអាមួយត្រូវជាក្មួយខ្ញុំដែលដឹកខ្ញុំទៅដល់វានិយាយថា ដល់ហើយរឿងបោកគ្រាប់បែកហ្នឹង

299- អ៊ាង : ហើយបានជួបនឹងឆាយវីដែរ ?

300- ធឿន : បាទ ! ជួបហើយបង

301- អ៊ាង : ជួបឆាយវីនៅឯណា ?

302- ធឿន : នៅក្រចេះ

303- អ៊ាង : នៅក្រចេះ ?

304- ធឿន : បាទ ! នៅក្រចេះ

305- អ៊ាង : ចុះពេលហ្នឹងឆាយវីឯងមានបានចូលមកភ្នំពេញវិញទេ ?

306- ឆាយវី : អត់ចូលទេ ! នៅក្រចេះរហូត

307- អ៊ាង : នៅក្រចេះរហូតអត់ដែលមកភ្នំពេញទេ ?

308- ឆាយវី : បាទ ! អត់ដែលទេ

309- អ៊ាង : ចុះពេលជួបប្រេស៊ីល ជួបនៅឯណា ?

310- ឆាយវី : ពេលជួបប្រេស៊ីល ជួបនៅកន្លែងធ្វើការ

311- អ៊ាង : ជួបប្រេស៊ីលទៀត ជួបលើកក្រោយដែលគាត់បានគប់គ្រាប់ ហើយបានជួបប្រេស៊ីលម្តង តើជួបនៅឯណា ?

312- ឆាយវី : ធឿនគេជួបប្រេស៊ីល ប្រេស៊ីលប្រាប់ធឿនថា គេលួចរត់

313- សូម៉ូរ៉ា : ឈប់សិន ! ខ្ញុំសុំសួរមួយ មិញថា ប្រេស៊ីលទៅផ្ទះធឿន ទៅជួបអ្នកណា ដែលនិយាយថា អ្នកទាំងប្រាំមួយនាក់ហ្នឹងចេញទៅបាត់ហ្នឹង ?

314- ធឿន : ប្រេស៊ីលប្រាប់ខ្ញុំ

315- សូម៉ូរ៉ា : អញ្ចឹង ម៉េចក៏ប្រេស៊ីលអត់ទៅជាមួយគេអញ្ចឹង ?

316- ធឿន : បាទ ! ទៅដែរ តែរត់រួចមកវិញ…

317- អ៊ាង : ធឿនឯង តាំងពីថ្ងៃដែលបែកចេញពីឆាយវីហ្នឹង ដែលត្រឡប់ទៅវិញទេ ?

318- ធឿន : អត់ផងបង អត់ដែលទៅសោះ ទូរស័ព្ទអីអត់ដែរ

319- អ៊ាង : នឹកឃើញម៉េចបានអត់ទៅ ?

320- ធឿន : ព្រោះខ្ញុំដឹងរឿងអាគេយកទៅ ដឹងរឿងធ្វើក៏ស្លាប់ ធ្វើហើយស្លាប់ ហើយខ្ញុំដឹងរឿងគេខ្ញុំប្រាកដជាស្លាប់ដែរហើយ ហើយគេតាមអោយទៅកន្លែងកុំខាន ខ្ញុំចេះតែគេចៗខ្លួនទៅរហូតមក

321- សូម៉ូរ៉ា : ហើយពេលណាដែលធឿនឯងនឹកឃើញថាចង់មកជួបសម រង្ស៊ី ?

322- ធឿន : ក្រោយមក យូរដែរ ប្រហែលជាប្រាំបីប្រាំបួនខែ បានទៅជួបមនុស្សម្នាក់ថា នៅអង្គរក្សព្រះអង្គម្ចាស់ និយាយប្រាប់ដំណើរទំនងថា ទៅជួយបំភ្លឺឯកឧត្តម សមរង្ស៊ី ទៅក្រែងលោមានជាប់ឆ្នោតជាប់អីទៅ យើងអាចស្រួលខ្លួនបន្តិច ហើយបើថា មិនទៅជួយស្រួលទេ ជួយបំភ្លឺគាត់ទេ គេចេះតែចោទទំលាក់លើគាត់ថាគាត់នាំបាតុកម្មហើយសំលាប់មនុស្ស

323- សូម៉ូរ៉ា : អង្គរក្សព្រះអង្គម្ចាស់ហ្នឹង ធឿនឯងស្គាល់តាមរយៈអ្នកណា ?

324- ធឿន : តាមក្មួយខ្ញុំ ក្មួយខ្ញុំរត់ម៉ូតូឌុប

325- អ៊ាង : ហើយពេលជួបលោកហ្នឹង ធឿនឯងប្រាប់គាត់ថាម៉េច ?

326- ធឿន : បាទ !

327- អ៊ាង : ជួបអង្គរក្សព្រះអង្គម្ចាស់ រណឫទ្ធិ ?

328- ធឿន : ទៅដល់វាយកខ្ញុំទៅផ្ទះហ្នឹងទាំងយប់ ខ្ញុំថាមិនដឹងជានិយាយថាម៉េចទេ បានក្មួយខ្ញុំប្រាប់ថា បើសិនជាយើងទៅជួយបំភ្លឺជាមួយឯកឧត្តម សម រង្ស៊ីទៅ យើងអាចសុខខ្លួនហើយ យើងអាចធ្វើអីគេមិនកើតទេ អាចបានសុខស្រួលខ្លះ ហើយក៏ពិភាក្សាគ្នាជាមួយកូនចៅច្រើន ហើយខ្ញុំក៏គិតឃើញថាប្រថុយអីចឹង តែខ្ញុំថា ខ្ញុំមិនមែនអ្នកធ្វើទេ គ្រាន់តែថា ខ្ញុំអ្នកដឹងរឿង ព្រោះខ្ញុំនៅក្នុងអង្គរក្ស ខ្ញុំដឹងរឿងទាំងអស់ ធ្វើអីៗហ្នឹងខ្ញុំដឹង តែខ្ញុំចង់ទៅបំភ្លឺ ដល់ខ្ញុំមកឈរមុខហ្នឹងវា ចូលទៅជួប ខ្ញុំមិនទុកចិត្តដែរហ្នឹង ឃើញអ្នកខ្លះមើលមុខខ្ញុំប្រុងឡើងម៉ូតូទៅវិញហើយហ្នឹង ដល់រួចបានគេអោយចូល បានខ្ញុំដាច់ចិត្តថា ដើរចូលទៅ តែដល់ចូលទៅជួបបងនៅកន្លែងហ្នឹង តាំងពីថ្ងៃហ្នឹងមក ខ្ញុំដូចជារាងធូរចិត្តបន្តិច ខ្ញុំថារឿងហ្នឹងអញ្ចឹង ខ្ញុំសុខចិត្តទៅស្រាយបំភ្លឺ ហើយខ្ញុំនៅផ្ទះក៏មិនសុខដែរ ព្រោះគេតាមរកដដែលទៅដូចចោរអញ្ចឹង ទៅមួយភ្លែតៗ

329- អ៊ាង : ប៉ុន្តែខ្ញុំចង់សួរមួយ ឆាយវី នៅពេលធឿនបានជួបឆាយវីឯង ចុងក្រោយនេះរហូតថ្ងៃនេះ តើឆាយវីឯងក្នុងចិត្តមានភ័យថា ខ្លាចមានទោសទេ ខ្លាចមានទោស ?

330- ឆាយវី : រឿងធឿន គេទៅជួបខ្ញុំគេនិយាយពីបញ្ហារឿងគណបក្ស សម រង្ស៊ីអញ្ចេះមួយៗ ណាបងណា ខ្ញុំកំពុងតែគិត ខ្ញុំកំពុងតែទាមទារ ដូចថាស្មោះត្រង់ ហើយដូចថារកសន្តិភាព ក្នុងខ្លួនផងណាមួយរឿងប្រទេសជាតិយើងផង ព្រោះខ្ញុំធ្លាប់រៀនរូបមន្ត ប៉ុន្តែអារឿងច្បាប់ខ្ញុំមិនដែលចេះទេ ព្រោះតែខ្ញុំក៏មិនដែលគិត ឃើញថានៅកន្លែងនោះអោយគេចូល ចូលក្នុងផ្សារ ខ្ញុំមិនហ៊ានចូលទេ ខ្ញុំមិនទាន់ទុកចិត្តធឿននោះទេ អ្នកណាក៏ខ្ញុំមិនទុកចិត្តពេលនោះ ខ្ញុំលែងទុកចិត្តវាហើយវាលែងទុកចិត្តមួយសា ដូចថាមួយញាំវម៉ាបន្តិចហ្នឹងឯង ខ្លាចធឿននេះនាំខ្ញុំទៅដាក់ក្នុងពេលក្រុមវានោះ រួចខ្ញុំក៏ជាប់អញ្ចេះខ្លាចខ្ញុំចាញ់នយោបាយត្រង់ហ្នឹង បានខ្ញុំសង្កេតតាមដានវាទៅ វាក៏មិនមែនខ្ញុំក៏ប្រថុយខ្លួនចូលក្នុងគណបក្ស សម រង្ស៊ីហ្នឹង

331- អ៊ាង : ជួបគាត់ ?

332- ឆាយរី : បាទ ! មកជួបគាត់

333- អ៊ាង : ប៉ុន្តែមានភ័យទេ ?

334- ឆាយរី : ភ័យបងភ័យ

335- អ៊ាង : ភ័យខ្លាចថាមានទោសទេ ?

336- ឆាយរី : បាទ ! ភ័យខ្លាចមានទោស ខ្លាចគាត់មានគំនុំលើខ្ញុំព្រោះចិត្តមួយៗ ចង់សំលាប់គាត់ ប៉ុន្តែខ្ញុំមិនដឹងរឿងទេប៉ុន្តែគ្រាន់ថាលោកគ្រាប់បែកប្រៀបធៀបដូចសំលាប់គាត់អញ្ចឹង បាទ ! ប៉ុន្តែពេលខ្ញុំចូល ខ្ញុំភ័យខ្លាច ប៉ុន្តែពេលខ្ញុំចេញមកវិញ ឬមួយបំរើនយោបាយណាមួយ ខ្ញុំអត់ដឹងទេ ហើយដល់ពេលខ្ញុំមកជួបគាត់ជួបពួកបង ជួបបងលើកទីមួយ មិនអញ្ចឹង ? នៅពេលបងនិយាយសំណេះសំណាលទៅដូចជាមិនអី ដូចជាបានធូរចិត្ត ដូច្នេះ ខ្ញុំហាក់ដូចជាលែងភ័យព្រួយ ហើយ ក៏ត្រជាក់ចិត្ត

337- អ៊ាង : ប៉ុន្តែចូលភ្នំពេញហ្នឹង តើការជិះឡានចូលភ្នំពេញហ្នឹងមានអារម្មណ៍ ?

338- ឆាយរី : មានអារម្មណ៍ខ្លះដែរ មានអារម្មណ៍ខ្លាចថា មានគេស្គាល់ ប៉ុន្តែនៅក្នុងខ្លួនរបស់ខ្ញុំនេះ កុំថាឡើយគេស្គាល់ សូម្បីប្រពន្ធខ្ញុំក៏អត់ដឹងដែរ ក្នុងចំណោមអង្គភាពខ្ញុំក៏គេមិនដឹងថា ខ្ញុំធ្វើការនេះដែរ គឺដឹងតែលោកធឿននេះនិងខ្ញុំទេ ដែលដឹងអីចឹង ខ្ញុំអាចការពារសុវត្ថិភាពខ្ញុំបាន តែខ្ញុំក៏មិនទាន់ទុកចិត្តច្បាស់ខ្លួនឯងដែរ

339- អ៊ាង : ហើយធឿនហ្នឹង ជឿទេថា ពេលជួបឆាយរីនឹងនិយាយឲ្យឆាយរីមកជួបនឹងលោក សម រង្ស៊ី បានមែន ?

340- ធឿន : បាទ !

341- អ៊ាង : ជឿអញ្ចឹងតែម្តង ?

342- ធឿន : បាទ ! ជឿអញ្ចឹងតែម្តង បាទ ! ព្រោះខ្ញុំប្រាកដ ប្រាកដបើអត់ លែងខ្លាចងាប់ហើយ

343- អ៊ាង : ហើយធឿនឯង ពេលដែលជួបឆាយរីហ្នឹង និយាយប្រាប់ឆាយរីថាម៉េចខ្លះ ?

344- ធឿន : ខ្ញុំនិយាយប្រាប់ថា អារឿងដែលឆាយរីឯងបានធ្វើហ្នឹង ឥឡូវអញ្ចេះ អោយយើងរត់ទៅណេះពីនេះទៅនោះ អត់ផ្លូវដើរអញ្ចឹងទៅ ឥឡូវចូលខ្លួនទៅសារភាពកំហុស និងប្រាប់ទៅឯកឧត្តមសម រង្ស៊ីទៅ គាត់មិនយកទោសពៃរ៍អីទេ ដើម្បីអោយគាត់យករឿងហ្នឹងទៅ ឆ្លើយបំភ្លឺជាមួយថ្នាក់លើៗទៀត កុំអោយនៅជាប់ពាក់ពិន ។ ដំបូង ពេលទៅនិយាយខ្ញុំអត់ព្រមមកទេ ដល់ចេះតែនិយាយបញ្ចុះបញ្ចូល គេទៅប្រាប់តាមហ្នឹងថា បើមិត្រភក្តិបើឯងយកអញទៅសំលាប់ យកទៅ ងាប់ទៅក៏លែងស្តាយដែរ តែចងកម្មពៀរឯងរហូត ខ្ញុំថា មិត្រភក្តិដើរជាមួយគ្នារាប់ឆ្នាំហើយ នៅមិនស្គាល់ចិត្តគ្នាចេះតែនិយាយទៅ បានសុខចិត្តទៅតាមហ្នឹងណា អាលើកមុនហ្នឹងគ្រាន់តែយកទៅដល់គីឡូម៉ែត្រលេខ ៧ និងគ្រាន់តែដាក់ឡានចុះហើយប្រាប់បងឯងថា មកហើយហ្នឹង ភ័យបាត់ខ្ញុំ បានតាមមួយសាទៀតហ្នឹង

345- អ៊ាង : ឆាយរីឯងអង្គរក្ស ហ៊ុន សែន ក្រៅពីធឿន មានស្គាល់អ្នកណាផ្សេងទៀតដែរឬទេ ? អង្គរក្ស ហ៊ុន សែន ?

346- ឆាយរី : ខ្ញុំស្គាល់ ខ្ញុំស្គាល់ ម្នាក់ពីរនាក់អ្នកធំត្រយោង

347- អ៊ាង : ប៉ុន្តែអ្នកផ្សេងទៀត ?

348- ឆាយរី : អត់មានស្គាល់ទេ

349- អ៊ាង : អត់មានស្គាល់ទេ ? ហើយ ហ៊ីង ប៊ុនហៀងក៏ស្គាល់អត់ច្បាស់ ?

350- ឆាយរី : អត់ច្បាស់ទេ បើទោះជាឃើញគាត់

351- អ៊ាង : តើរូបរាងគាត់យ៉ាងដូចម្តេច ពេលជួបគាត់ហ្នឹង ?

352- ឆាយរី : ជួបហ្នឹងមិនមែនដូចជួបជាមួយបងអីចឹងៗទេ មិនយូរទេ ជួបប្រហែលជាប្រាំនាទីអីទេ ហើយបើលោកនេះប្រាប់ខ្ញុំថាហ៊ីង ប៊ុនហៀង ក៏ខ្ញុំអាចចំណាំមុខដែរ ហើយបើខ្ញុំសំឡឹងមើលមុខគាត់ ឬគោរពគាត់ តែវាមិនទាន់ប្រាប់ខ្ញុំហើយក៏មិនសួរ ចាប់ភ្លឹកឬមួយអ្នកនោះកូនទាហានគេ ឬមួយជាស្នំគេ ខ្ញុំក៏មិនដឹង មិនសួរចាប់ភ្លឹក បើសិនខ្ញុំស្គាល់គាត់ថា ជាហ៊ីង ប៊ុនហៀង ខ្ញុំក៏ចាប់ភ្លឹកដែរ...

353- អ៊ាង : ពេលនោះបានជិះឡានមកជាមួយគ្នាទៀត ?

354- ឆាយរី : បាទ ! ជិះឡានមកជាមួយគ្នា... ខ្ញុំជិះពីក្រោយគាត់

355- អ៊ាង : ឆាយរីឯងអត់ចាប់ភ្លឹក ?

356- ឆាយរី : អត់ចាប់ភ្លឹក ទាល់តែខ្ញុំចុះពីលើឡាន បានប្រាប់ថាឯងអត់ស្គាល់ទេហ្នឹង ហ៊ីង ប៊ុនហៀងប្រធានអង្គរក្ស បានខ្ញុំចាប់ភ្លឹកថាអូ !...

357- អ៊ាង : ប៉ុន្តែធឿនឯងស្គាល់ច្បាស់តែម្តង ហ៊ីង ប៊ុនហៀងហ្នឹង ?

358- ធឿន : ...

359- អ៊ាង : ហើយគាត់ស្គាល់ធឿនឯងច្បាស់តែម្តង ?

360- ធឿន : បាទ !

361- អ៊ាង : ឥឡូវ តើធឿនឯងហ៊ានទេ បើខ្ញុំនាំធឿនឯងទៅជួបហ៊ីង ប៊ុនហៀង ?

362- ធឿន : ហ៊ានបង !

363- អ៊ាង : ហ៊ានទៅជួបគាត់ដែរ ?

364- ធឿន : បាទ ! អោយតែបងឯងការពារសុវត្ថិភាពខ្ញុំ ខ្ញុំហ៊ានទៅ...

365- អ៊ាង : ហ៊ានទៅជួបតែម្តង ! អត់ខ្លាចគេចាប់ទេ ?

366- ធឿន : អ្ហូ ! អាហ្នឹងលើបងឯងជាអ្នកការពារសុវត្ថិភាពរបស់ខ្ញុំ...

367- អ៊ាង : គាត់បាញ់ ! បងប្អូនទាំងអស់គ្នាកុំបារម្ភ ឥឡូវក្នុងចិត្តមានខ្លាចថា អ្នកដែលដឹងរឿងៗ ខ្ញុំដឹងរឿងអីហ្នឹង នឹងនាំឆាយវីឯងទៅអោយប៉ូលិស ទៅអោយអី ភ័យខ្លាចអញ្ចឹងទេ ?

368- ឆាយវី : ក្នុងចិត្តខ្ញុំបារម្ភត្រង់នេះទេ ត្រង់ថាបើកាលណាការងារនេះមិនទាន់សំរេច ហើយយកឈ្មោះខ្ញុំទៅផ្សព្វផ្សាយ គឺខ្ញុំពិបាកត្រង់ហ្នឹង ខ្ញុំសំណូមពរថា បើការនេះមិនទាន់ធ្វើកើត ឬមួយអ្វីមួយយើងកុំអាលធ្វើខុសណាបងណា ការហ្នឹងខ្ញុំពិបាក

369- អ៊ាង : ប៉ុន្តែប្រសិនបើគេ មានគេ ដូចខ្ញុំអញ្ចឹងជាដើម អោយទៅផុតអញ្ចឹងណា អញ្ចឹងយល់យ៉ាងណាដែរ ?

370- ឆាយវី : ក្នុងពេលខណៈនេះ បើកាលណាមិនផ្សព្វផ្សាយមិនអីទេ ខ្ញុំអាចការពារសុវត្ថិភាពខ្ញុំបានទេ

371- អ៊ាង : ប៉ុន្តែគេចង់ផ្សព្វផ្សាយ ប៉ុន្តែគេឲ្យមនុស្សទៅផុតអញ្ចឹងដែរ ?

372- ឆាយវី : ខ្ញុំដូចមិនចង់ចេញមកដែរទេ

373- អ៊ាង : មូលហេតុអី ?

374- ឆាយវី : គ្មានមូលហេតុអី គ្រាន់តែមិនចង់ចេញ

375- អ៊ាង : ធម្មតាម៉េចបានមិនចង់ចេញ គេផ្គត់ផ្គង់ អីធម្មតា ដូចថាមកនៅអីចឹងណា ហើយដល់ពេលគេចង់ធ្វើការអ្វីមួយ តើអាចបានទេ ?

376- ធឿន : អាហ្នឹង សុំមួយរយៈសិន ទាល់នាំប្រពន្ធនាំកូនមក តែចាំវិភាគជាមួយបងប្អូនសិន

377- អ៊ាង : បើចង់វិភាគ ទាល់តែប្រពន្ធសួរដេញដោល ប្រពន្ធសួរថាចុះម៉េចឯង ក៏ឆាយវីឯងថា ប្រពន្ធកូនអត់ដឹងរឿងទេ ?

378- ឆាយវី : បាទ ! អត់ដឹងរឿងទេ

379- អ៊ាង : បើយើងមិនមានការអី យើងមកនៅស្រុកថៃចាំគេជួយមើលការខុសត្រូវយើង...

380- ធឿន : ត្រង់នេះពិបាកនិយាយជាមួយប្រពន្ធថាឯង ទៅនៅឯនោះទៅ នៅនេះពិបាករកស៊ី ទៅឯនោះគេមានលុយចិញ្ចឹម គេមានបាយហូបមានអីអញ្ចឹងទៅ អោយលក់ដីលក់អីអញ្ចឹងមក ហើយមកនេះ អាហ្នឹងទាល់តែគេផ្តិតមេដៃគ្នាជុំគ្នាសិន ទើបហ៊ានសំរេច

381- អ៊ាង : ហើយជូនណាអាច អាចបង... ជូនណាគេអាចជួយប្រពន្ធកូនអោយ...គេសុខចិត្តជួយជាក់ស្តែងគ្រាន់ថា ឲ្យឆាយវីឯងមកតំបន់មួយមានសុវត្ថិភាពមានសុវត្ថិភាព ហើយដើម្បីអោយគេធ្វើការ ព្រោះបើគេប្រកាសជាចំហ ដើម្បីធ្វើការស៊ើបអង្កេត អាហ្នឹងឈានដល់ករណីហ្នឹងណា

382- ធឿន : អញ្ចឹង...បងអាចនិយាយថា បើសិនជាខ្ញុំអ្នកធ្វើវិញ ខ្ញុំដាច់ចិត្តជាងនោះភ្លាម តែនៅទាក់ទាមរឿងកូនប្រពន្ធ ខ្ញុំដាច់ភឹងៗហើយ ។

383- អ៊ាង : អូ ! ភ្លេចសួរ ម៉ូតូហ្នឹងទិញម៉ាកអី ?

384- ឆាយវី : ហ្សុីអ៊ែរ

385- អ៊ាង : ហ្សុីអ៊ែរ ទិញនៅភ្នំពេញ ?

386- ឆាយវី : ទិញនៅភ្នំពេញ

387- អ៊ាង : ទិញនៅម្តុំណា ?

388- ឆាយវី : នៅអូរឫស្សី

389- អ៊ាង : អូរឫស្សី ដល់លក់ៗនៅកំពង់ចាម ?

390- ឆាយវី : កំពង់ចាម

391- អ៊ាង : លក់ខាតប៉ុន្មាន ?

392- ឆាយវី : ទិញមកប្រាំបីរយ លក់បានប្រាំពីររយចិតប្រាំពីររយប៉ែតដែរ

393- អ៊ាង : ជិះបានប៉ុន្មានថ្ងៃ ?

394- ឆាយវី : បើតាមគិតទៅ មិនដល់មួយអាទិត្យទេ អត់ដល់មួយអាទិត្យទេ បើតាមគិតទៅ បានប្រហែលប្រាំថ្ងៃទៅប្រាំមួយថ្ងៃ

395- អ៊ាង : ហើយនៅពេលដែលគាត់ហុចលុយអោយ នៅពេលឡានឈប់ ឬ មុនចុះពីឡាន ?

396- ឆាយវី : អោយក្នុងឡាន

397- អ៊ាង : ក្នុងឡានពេលគាត់ឈប់ អោយ ឬក៏...

398- ឆាយវី : ក្នុងឡាន ពេលបើក ពេលហុចលុយហ្នឹងក៏មិនមើលមុខខ្ញុំផង ។ អោយធឿនហុចអោយ...

399- អ៊ាង : រួចហើយបានគាត់ថា បើបានសំរេច...

400- ឆាយវី : បាន បានលុយ

401- អ៊ាង : ឥឡូវអោយមួយពាន់ចាយសិន ?

402- ឆាយវី : អោយមួយពាន់ចាយសិន

403- សូម្ម៉ារា : ហើយគាត់អត់ប្រាប់ថា ពេលណាឲ្យទៅយកលុយប្រាំបួនពាន់ដែលនៅសល់ ?

404- ឆាយវី : ពេលបែកហើយ អោយទៅយក

405- សូម្ម៉ារា : អញ្ចឹង ! បើបែកហើយអោយទៅតាមភ្លាមៗ គាត់ប្រាប់ថា អោយទៅវត្តបទុមតែម្តង ?

406- ឆាយវី : បាទ ! អោយតែផ្ទះ...

407- សូម្ម៉ារា : អីចឹងបានន័យថា គ្រាប់បែកហើយភ្លាមៗហ្នឹង ចូលយកលុយ

408- ឆាយវី : អត់មានទេ ! ហើយចូលទៅហ្នឹងហើយ តែមិនមែនចូលទៅយកលុយទេ ចូលទៅរកគេចខ្លួនទេ ប៉ុន្តែដោយមើលក្នុង

ទាហានមួកសំណាញ់ប៉ុន្មាននាក់ហ្នឹង ខ្ញុំមើលសភាពវាមិនស្រួល ហើយបើស្រួល ខ្ញុំចូលទៅមុនគេ គ្មានអ្នកណាគេនៅខាងក្នុងដែរ មានសុទ្ធតែទាហានទាំងអស់ ហើយក៏មិនដឹងជាអ្នកណាៗទេ ខ្ញុំក៏ប្រឹងគេចខ្លួន

409- សូម្ភ៉ា : ហើយចុះលោកឯងពេលហ្នឹង ម៉េចមិននឹកឃើញថារកហ៊ីង ប៊ុនហៀង ទៅទារគាត់ ព្រោះគាត់ប្រាប់ថាបោកគ្រាប់បែកផ្ទុះហើយ ទៅរកគាត់វិញ ?

410- ឆាយវី : អីចេះអត់មានទេ ! បង ! ព្រោះខ្ញុំដឹងខ្លួនខ្ញុំដែរបងពេលធ្វើហើយ បានខ្ញុំដឹងក្នុងចិត្តថា ខ្ញុំពេលនេះ ខ្ញុំដឹងថាចាញ់បោកចាញ់ប្រាជ្ញាគេហើយ ព្រោះពេលខ្ញុំធ្វើការនេះហើយគួរតែគេចាំទទួលខ្ញុំ ឬមួយអាហ្នឹងវាបែក ពេលធ្វើហើយបែរជាគ្មានមនុស្សនៅក្បែរសុទ្ធតែគ្នាគេទាំងអស់ ទាហាន ឬមួយទាហានម៉េចៗក៏ខ្ញុំអត់ដឹងដែរ ព្រោះថា មិនទំនង គេចង់ស៊ី ឬគេចង់ធ្វើអី ខ្ញុំមិនបានសួរនាំគេ គេក៏មិនបានសួរនាំខ្ញុំដែរ ខ្ញុំគេចខ្លួនទៅភ្លាម

411- អ៊ាង : ពេលដែលបោកហើយមានមើលទៅក្រោយទេ ?

412- ឆាយវី : ខ្ញុំ អើ មិនមែនថាមិនមើលទេ មើលខ្លះដែរ ប៉ុន្តែវាព្រិល វារាងហ្នឹង តែមានគេតាមពីក្រោយ តែមិនដឹងជានរណាទេ

413- អ៊ាង : ពេលរត់ហ្នឹង ?

414- ឆាយវី : ពេលរត់ តែមិនដឹងជាអ្នកណាទេ អត់ដឹង

415- សូម្ភ៉ា : ពេលបោះហើយ...

416- ឆាយវី : បាទ ! បោះហើយខ្ញុំរត់ ហើយមានគេតាម តែមិនដឹងជានរណាៗ

417- អ៊ាង : ហើយទាហាន ដែលគេយាមនៅហ្នឹង ក៏គេព្រលែង ?

418- ឆាយវី : គេមិនព្រលែងទេ ថាគេព្រលែងថាក៏គេចុះ គេមិនរវល់នឹងខ្ញុំទេណា គេកំពុងតែស្អីណាការពារខ្លួនស្អីណា ពេលនោះគេរកកន្លែងណានៅទេ ប៉ុន្តែគេមិនបានឃាត់ខ្ញុំទេ ហើយគេក៏មិនបានហៅសួរនាំខ្ញុំដែរ ពេលកំពុងតែជ្រួលច្របល់ ខ្ញុំទៅ គេត្រៀមខ្លួនគេ គេមិនហាមឃាត់ខ្ញុំជាជនស៊ីវិល បើឃើញទាហានទំនងអីចេះអីចុះដែរ ខ្ញុំក៏...

419- ធឿន : ព្រោះកន្លែងនោះ សុទ្ធតែជាកំលាំងរបស់ខ្ញុំ កំលាំងអង្គរក្ស

420- ឆាយវី : ព្រោះគេថា ខ្ញុំពួកក្រុមបាតុកម្មគេក៏អត់ដឹងរឿងគេខ្ញុំអត់ដឹង ។

421- សូម្ភ៉ា : ហើយអ្នកដែលបោះសញ្ញា បោះសញ្ញានោះ

422- អ៊ាង : បោះក្រដាស...

423- សូម្ភ៉ា : បោះក្រដាស ឬ បោះកន្ទុយបារី...?

424- ឆាយវី : អូ អា ! បោះជាសញ្ញាហ្នឹងណា ! អត់ទេ មានក្រដាសមួយស ដូចជាក្រដាសកាសែត វាមូរអីអញ្ចឹងៗបោះចំកែងបណ្តោយ បោះចំកន្លែងដូចជាថាបងនៅត្រង់នេះចំងាយហ្នឹង...

*(កំពុងគូរគំនូសតាង)*

425- សូម្ភ៉ា : គូរផ្លូវសភា នេះវាំង នេះផ្លូវជាប់វាំង នេះរដ្ឋសភា

426- អ៊ាង : នេះវាំង រាជវាំង នេះរដ្ឋសភា ផ្លូវមុខវត្តបទុមកន្លែងបាតុកម្មនេះ អ្នកដែលបោះក្រដាសបោះកន្លែងណា ?

427- ឆាយវី : បោះនៅត្រង់នេះ

428- អ៊ាង : បោះខាងនេះវិញ ?

429- ឆាយវី : បាទ ! នៅខាងចុង

430- អ៊ាង : បានន័យថា ឆាយវីឯង បើពេលចុះ ចុះនៅត្រង់ណា ?

431- ឆាយវី : ខ្ញុំចុះនៅក្រោមដើមស្អី ដើមមៀន...

432- អ៊ាង : ហើយ អ្នកដែលបោះក្រដាសបោះនៅកន្លែងណា ?

433- ឆាយវី : បោះក្រដាស បោះទីបីទីពីរម្តុំចំមុខបណ្តោយ អាមុខគេហ្នឹង

434- អ៊ាង : ក្រដាស ក្រដាស

435- ឆាយវី : ក្រដាសដែលគេបោះស៊ីញ៉ូមកហ្នឹង ? គេបោះមិនចំជ្រុងហ្នឹងទេ គេបោះរាងចុងកណ្តាលនិងចុង

436- អ៊ាង : នេះបាតុកម្ម

437- សូម្ភ៉ា : ខាងនេះសភា

438- ឆាយវី : សភា

439- សូម្ភ៉ា : ឈប់ៗ ឆាយវីឯង លោកវីឯងឈរនៅត្រង់ណា...?

440- ឆាយវី : ខ្ញុំឈរនេះ ឈរកន្លែងដើមមៀនហ្នឹង ហើយអាផ្លូវកែង

441- សូម្ភ៉ា : ខ្ញុំចង់ដឹងថាឈរនៅកន្លែងណា ពេលបោះស៊ីញ៉ូហ្នឹង ?

442- ឆាយវី : ពេលបោះស៊ីញ៉ូ ខ្ញុំនៅពីក្រោមដើមអំពិលនេះ ខ្ញុំទៅដល់ក្រោមដើមអំពិល បោះពីក្រោយខ្ញុំឆ្លងផ្លូវ

443- អ៊ាង : ប៉ុន្តែអ្នកដែលបោះក្រដាស មូរក្រដាសសញ្ញាហ្នឹង គេឈប់នៅណា ?

444- ឆាយវី : បើបញ្ជាក់បន្តិច ខ្ញុំមិនដឹងដែរ ខ្ញុំនៅពីក្រោយគ្រាន់តែឃើញបោះប៉ុណ្ណឹង

*(អ្នកសំភាសន៍កំពុងទទួលទូរស័ព្ទ)*

445- សូម្ភ៉ា : ឈប់ៗ ឡើងជិះម៉ូតូនៅត្រង់កន្លែងណា ?

446- ឆាយវី : ឡើងជិះកន្លែងខាងក្រោយ វត្តស្អីគេនេះហើយ បានគេបើកផ្លូវនោះមក ចេញខាងវាលមេរុ

447- សូម្ភ៉ា : អូ ! វាងអញ្ចឹង ឡើងម៉ូតូនៅកន្លែងមុខវត្តបទុមក្នុងវត្តបទុម...

448- ឆាយរី : នៅក្នុង នៅខាងក្រោយ...

449- សូម៉ូរា :អញ្ចឹង មិនមែនមានន័យថា មិនមែននៅក្នុងវត្តបទុម ទេ...

450- អ៊ាង : នៅក្នុងប្លុកហ្នឹងហើយ ប៉ុន្តែប្លុកវាធំ

451- សូម៉ូរា : រួចទៅ វាងទៅដល់សារមន្ទីរ

452- ឆាយរី : ទៅវាលមេរុ ហើយបានជិះកាត់មុខវាំងមកវិញ...

453- សូម៉ូរា : ហើយម៉ូតូឈប់នៅត្រង់កន្លែងណា ?

454- ឆាយរី : ពេលមក ខ្ញុំឈប់នៅ...

455- សូម៉ូរា : ក្រោមដើមមៀន រួចម៉េចទៅ ពេលម៉ូតូឈប់ហ្នឹង លោកឯងឈប់ត្រង់ហ្នឹង ឬក៏ទៅណាទៀត ?

456- ឆាយរី : ខ្ញុំចុះនៅត្រង់នេះ ដល់ពេលចុះនៅត្រង់នេះប្រហែល ប្រាំនាទីប្រាំមួយនាទីហ្នឹង គេមក ប៉ុន្តែបាតុកម្មគេនៅនេះហើយ ខ្ញុំក៏ឆ្លងផ្លូវទៅនៅក្រោមដើមអំពិលនេះវិញ

457- សូម៉ូរា :អូយេ! ពេលដែលម៉ូតូលោកឯងមកដល់ហ្នឹង តើពួកបាតុករ គេមកដល់ហើយឬនៅ ?

458- ឆាយរី : គេមកដល់ហើយ

459- សូម៉ូរា : គេមកដល់មុនយូរហើយ ?

460- ឆាយរី : បាទ !

461- សូម៉ូរា : ចុះពេលលោកឯង ពេលដែលម៉ូតូឈប់ហ្នឹង ប្រហែលខ្ទង់ម៉ោងប៉ុន្មាន ? ចាំទេ ?

462- ឆាយរី : អត់បានចាំផង...

463- សូម៉ូរា : មានទាំងអស់គ្នានៅហ្នឹងហើយ ?

៤៦៤- ឆាយរី : បាទ! ហើយដល់ពេលខ្ញុំមក ខ្ញុំមកតែឯងទេ ខ្ញុំមិនដឹងគេមកពីស្ទើណាអីស្ទើណា ខ្ញុំអត់ដឹងទេ ប៉ុន្តែពេលខ្ញុំជិះមក ខ្ញុំជិះតែឯងទេ មិនដឹងជាអ្នកណាទេ ប៉ុន្តែមិនទាន់ដឹងគេមកមុនខ្ញុំ ឬស្អី ខ្ញុំមិនដឹងទេ ម៉ូតូឈប់ហ្នឹង ខ្ញុំមិនទាន់ដឹងថាឈប់ត្រង់ណាៗ ទេ ប៉ុន្តែអ្នកជិះម៉ូតូមួយមុខ គេអោយបោះក្រដាស ឬមួយស្អីត្រង់ហ្នឹង ខ្ញុំឈប់នៅត្រង់ហ្នឹង ប៉ុន្តែមិនមែនខ្ញុំអ្នកអោយឈប់ទេណា

465- សូម៉ូរា : អញ្ចឹង ! មានម៉ូតូមួយមុខបោះក្រដាស ?

466- ឆាយរី : បាទ ! ហើយខ្ញុំឈប់នៅត្រង់នេះ

467- អ៊ាង : ម៉ូតូឆាយរីឯងឈប់ត្រង់ហ្នឹង ?

468- ឆាយរី : បាទ !

469- សូម៉ូរា : បោះក្រដាស ក្រដាសយ៉ាងម៉េចទៅក្រដាសឆ្នូលមូរ អញ្ចឹងទៅ ?

470- ឆាយរី : បាទ ! មូរដូចក្រដាសកាសែត

471- សូម៉ូរា : អស់ប៉ុណ្ណឹងទៅ អាម៉ូតូហ្នឹងវាឈប់ទៅ ហើយគេប្រាប់ឆាយរីឯងចុះទៅ ?

472- ឆាយរី : បាទ ! គេថាបងឯងចុះទៅខ្ញុំក៏ចុះត្រង់ហ្នឹងទៅ ខ្ញុំឈរមើលចុះមើលឡើងៗអញ្ចឹងទៅ ក៏ឃើញក្រែងលោមានគ្នាច្រើន ស្មានខ្ញុំតែឯង ខ្ញុំក៏ដើរឆ្លងទៅរកកន្លែង ក្រោមដើមអំពិលនេះ

473- សូម៉ូរា : អ្នកណាប្រាប់អោយទៅក្រោមដើមអំពិលហ្នឹង ?

474- ឆាយរី : ខ្ញុំទៅខ្លួនឯងទេ

475- សូម៉ូរា : លោករីឯងអត់មានទទួលបញ្ជាអីពីអ្នកណាទាំងអស់ ?

476- ឆាយរី : អត់មានទទួលអីទាំងអស់

477- សូម៉ូរា : អត់មានប្រាប់ថា អោយឈរត្រង់ណាអីត្រង់ណីទេ ?

478- ឆាយរី : បាទ ! អត់មានទេ...

479- សូម៉ូរា : រួចហើយ ដើរទៅ ឆ្លងក្រោមដើមអំពិលនេះ

480- ឆាយរី : បាទ !

481- សូម៉ូរា : រួចទៅ !

482- ឆាយរី :រួចទៅឃើញអាប្រេស៊ីល ប្រេស៊ីលមួយហ្នឹង ដែលគប់ ប្រេស៊ីលហ្នឹងដែលគប់លើកទីមួយ នៅអែបត្រង់សភាគប់ទៅណាទៅណាមិនដឹង កំពុងតែយាអញ្ចេះ វាងាកទៅខ្ញុំក៏ចាប់ផ្តើមឆ្លងមកខាងសួនច្បារនេះវិញ

483- សូម៉ូរា : អញ្ចឹងឃើញប្រេស៊ីលគប់ពីនេះមក ?

484- ឆាយរី : បាទ ! អែបសភា...

485- សូម៉ូរា : ជិតសភា ក្បែរបងសភា ឃើញប្រេស៊ីលគប់គ្រាប់បែកហើយ

486- ឆាយរី : បាទ !

487- សូម៉ូរា : រួចពីប្រេស៊ីលគប់គ្រប់បែកទៅ លោកឯងដើរពីនេះទៅកន្លែងណានេះ

488- ឆាយរី : ខ្ញុំដើរ ក្នុងពេលនោះ ខ្ញុំបែរ...សួននៅខាងណេះ

489- អ៊ាង : ក្នុងសួនហ្នឹង ?

490- ឆាយរី : បាទ ! នៅកន្លែងហ្នឹង ខ្ញុំគប់ហើយ ខ្ញុំក៏គេចទៅ

491- សូម៉ូរា : អូ ! អញ្ចឹង ប្រេស៊ីលគប់ហើយ បានលោកឯងគប់

492- ឆាយរី : គ្រាប់ទីបួន ណោះ...

493- សូម៉ូរា : ចុះពេលណាដែលឃើញសញ្ញា ដែលគេបោះក្រដាសហ្នឹង ក្រែងត្រូវគប់នៅពេលណាគេបោះសញ្ញាទេឬ ?

494- ឆាយរី : បាទ ! ដល់ពេលគេបោះក្រដាសហើយ ប្រហែលជាប្រាំនាទី ខ្ញុំរត់មកខាងនេះ ប៉ុន្តែគ្រាន់តែមកដល់កន្លែងអានេះ លេងភ្លឺប ខ្ញុំក៏លេងទៅជាមួយវាហើយតែម្តង ។

495- សូម៉ូរា : អូ! សញ្ញាក្រដាសហ្នឹង មិនសំរាប់អោយគប់ទេឲ្យចុះពីម៉ូតូ ?

496- ឆាយរី : អត់ទេ ! បោះសញ្ញាត្រង់ណាគឺអោយគប់ត្រង់នោះ

497- សូម៉ូរា : ក៏ប៉ុន្តែ...

498- ឆាយរី : ខ្ញុំចុះពីលើម៉ូតូភ្លឹប ខ្ញុំចុះតឹប ម៉ូតូវាលឿង ខ្ញុំឈរប្រហែល ១៥នាទី មិនទាន់ឆ្លងកាត់នេះ ព្រោះក្នុងពេលបាតុកម្មនោះមិនទាន់ជុំឬមិនទាន់ស្អីខ្ញុំមិនដឹងទេណា បានប្រហែលជាប៉ុន្មានទៀត បានគេលេង អាប្រេស៊ីលវាលេងគប់ទៅបានខ្ញុំគប់ ឆ្លងមកខាងនេះ...

499- សូម៉្វារ៉ា : អញ្ចឹង បើតាមបញ្ហា គេអោយយើងហ្នឹងគឺចាំអោយតែមានអ្នកណាមួយគប់គ្រាប់បែកហើយ បានយើងបន្តទៀត ?

500- ឆាយរី : បាទ ! មិនមែន គេមិនអោយបន្តទេ គេសុំអោយលីសួរតែមួយផង គេចង់អោយលីសួរតែមួយផង តែធ្វើម៉េចឲ្យរួចខ្លួនផងដែរ ។

501- អ៊ាង : បើអញ្ចឹង ...

502- ឆាយរី : អោយគប់ត្រង់ណា អីត្រង់ណា គេមិនដឹងគេប្រាប់ឬអត់ទេ... ប៉ុន្តែរឿងខ្ញុំ គាត់អត់មានប្រាប់ទេត្រង់គប់ត្រង់ណាត្រង់ណាមិនដឹងទេ

503- អ៊ាង : អោយតែឮសូរផ្ទុះ...អោយផ្ទុះនឹងគេដែរទៅ ?

504- ឆាយរី : បាទ ! អោយផ្ទុះនឹងគេដែរទៅ

505- សូម៉្វារ៉ា : អញ្ចឹង ! សញ្ញាក្រដាសហ្នឹង គឺមិនមែនសញ្ញាអោយឈប់ម៉ូតូទេ រួចពីហ្នឹង អត់មានសញ្ញាអ្វីដទៃទៀតទេ ?

506- ឆាយរី : អត់ទេ ! សញ្ញានេះ សញ្ញាក្រដាស និងសញ្ញាម៉ូតូហ្នឹង ក្រដាសដែលខ្ញុំឈប់ហ្នឹង មិនមែន មិនមែនបោះក្រដាសអោយខ្ញុំឈប់ម៉ូតូទេណា ពេលម៉ូតូខ្ញុំឈប់ហ្នឹងអាអ្នកម៉ូតូឌុបដែលពាក់មួកហ្នឹង គេបោះសញ្ញាក្រដាសហ្នឹងអោយគប់ បានអានេះវាគប់ បានខ្ញុំក៏ឆ្លងកាត់ទៅហ្នឹង ម៉ូតូមិនទាន់មកទេ

507- អ៊ាង : ឈប់ៗ ខ្ញុំចង់អោយច្បាស់ បញ្ហាហ្នឹង ។ ឆាយរីឯងឈប់ម៉ូតូ ឆ្លងផ្លូវហើយឬនៅពេលគេបោះស៊ីញ៉ូក្រដាសហ្នឹង ?

508- ឆាយរី : នៅទេ ! ខ្ញុំឈរទេ មិនទាន់ឆ្លងទេ ខ្ញុំឆ្លងមកដល់នេះហើយបានគេបោះក្រដាស បានអានេះវាគប់ទៅនេះ មិនមែនបោះក្រដាសនេះ ឈប់ទេ មិនមែនទេ

509- សូម៉្វារ៉ា : អូយេ ! ខ្ញុំយល់ៗ លោកឆាយរីឯងថា អាម៉ូតូនេះជិះមុខហ្នឹង វាបោះក្រដាសទៅ បានម៉ូតូយើងនេះឈប់

510- ឆាយរី : មិនមែនទេៗ ម៉ូតូដែលខ្ញុំឈប់នេះ ម៉ូតូក្រោយ ម៉ូតូពាក់មួកស៊ីញ៉ូក្រដាសដែលគប់ហ្នឹង មិនមែនម៉ូតូបោះក្រដាសនេះគប់មិនងាប់ខ្ញុំត្រង់ហ្នឹងទេ...! ប៉ុន្តែមានបោះក្រដាសមួយត្រង់កន្លែងនេះ

511- អ៊ាង : ឃើញគេបោះក្រដាស ?

512- ឆាយរី : ឃើញបោះក្រដាស

513- សូម៉្វារ៉ា : ហើយៗ អ្នកបោះក្រដាសហ្នឹងជិះម៉ូតូ ?

514- ឆាយរី : ជិះម៉ូតូ ! ម៉ូតូគេទៅមុខហើយ មិនដឹងជាអ្នកណាជាអ្នកណាទេ សុទ្ធតែពួកហ្នឹងទាំងអស់ ប៉ុន្តែខ្ញុំស្គាល់តែអាប្រេស៊ីលហ្នឹងមួយ មិនស្គាល់គេច្បាស់ទេ គ្រាន់តែចំណាំ ចាប់ភ្លឹកមនុស្សហ្នឹង

515- សូម៉្វារ៉ា : រួចទៅ ! ម៉ូតូហ្នឹងបោះក្រដាសហើយប្រេស៊ីលគប់ភ្លាម

516- ឆាយរី : បាទ ! ប្រេស៊ីលគប់

517- សូម៉្វារ៉ា : ដល់អញ្ចឹង ! លោកឯង គប់ទៅ ?

518- ឆាយរី : នេះ គឺថា គប់តៗគ្នា រំលងកាត់សួនហ្នឹង

519- សូម៉្វារ៉ា : ពីក្រោមដើមអំពិលហ្នឹង ?

520- ឆាយរី : បាទ ! ពីក្រោមដើមអំពិលហ្នឹងទៅ

521- សូម៉្វារ៉ា : ចុះ ! អញ្ចឹង មានន័យថា គេបានប្រាប់លោករីឯងដឹងអញ្ចឹងថា អាស៊ីញ៉ូហ្នឹង គឺក្រដាសហ្នឹង ?

522- ឆាយរី : គឺក្រដាសហ្នឹង គឺថា បើឃើញទំលាក់ក្រដាសត្រង់ណា គឺត្រូវផ្ទុះនៅកន្លែងនោះ

523- សូម៉្វារ៉ា : អញ្ចឹង ក្រដាសនោះ បង្ហាញគោលដៅ ?

524- ឆាយរី : បាទ ! បង្ហាញគោលដៅ ពេលចេញ

525- សូម៉្វារ៉ា : បង្ហាញពេលវេលាផង បង្ហាញគោលដៅផង ?

526- ឆាយរី : បង្ហាញពេលវេលា ឬគោលដៅ គេបោះកន្លែងណា គឺយើងអត់មានពេលវេលាទេ បោះត្រូវន្លែងណាត្រូវគប់ត្រង់កន្លែងនោះ

527- សូម៉្វារ៉ា : ត្រូវហើយៗ ហើយក្រដាសនោះ វាត្រូវធ្លាក់ប្រហែលផ្ទុះនៅកន្លែងណា ?

528- ឆាយរី : ... ចំកណ្តាលថ្នល់ ចំចំហៀងថ្នល់រមៀលថ្នល់បន្តិច ខ្ញុំឆ្លងមកដល់នេះហើយណា ហើយបានគេមកក្រោយបានគេគប់មកនេះ ហើយបានខ្ញុំបោះខាងសួនច្បារ...ឯណោះវិញ

529- សូម៉្វារ៉ា : អញ្ចឹងៗ លោកឯងឈប់ឈរនៅក្រោមដើមអំពិលហ្នឹងទៀតហើយ ពេលដែលបោះគ្រប់បែកហ្នឹង ?

530- ឆាយរី : បាទ ! បាទ !

531- សូម៉្វារ៉ា : មកនៅឯណោះវិញហើយ ?

532- ឆាយរី : បាទ ! អត់ទេ ទីមួយឈប់នៅត្រង់នេះ ហើយបានឆ្លងផ្លូវនេះ មកនៅក្រោមដើមអំពិលនេះ បានម៉ូតូវាមក...

533- សូម៉្វារ៉ា : គេបោះក្រដាសទៅ ?

534- ឆាយរី : បាទ ! បោះក្រដាសទៅ ខ្ញុំស្គាល់អ្នកនោះ មិនដឹងអ្នកណាអ្នកណាទេ

535- សូម៉្វារ៉ា : រួចទៅ ដល់ពេលម៉ូតូហ្នឹង បោះក្រដាសហ្នឹងហើយនៅចំកណ្តាលថ្នល់ហ្នឹង ?

536- ឆាយរី : បាទ ! បានអានៅអែបនេះ គប់

537- សូម្ប៉ារ៉ា : ចា ! រួចហើយ...

538- ឆាយវី : គប់ហើយបានគេបន្ដៗរៀងគ្នាច្រើន មិនដឹងអ្នកណាទេ បានហើយ ខ្ញុំគប់ផុតអាទីបួនមកខាងសួនច្បារនេះ

539- សូម្ប៉ារ៉ា : ពេលហ្នឹងៗ ពេលគប់គ្រាប់បែកហ្នឹងតើលោកវីឯងនៅតែក្រោមដើមអំពិលដដែល ឬក៏បានដើរទៅខាងសួនច្បារហើយ ?

540- ឆាយវី : អត់ទេ ! ខ្ញុំដើរកាត់ផ្លូវហើយ ខ្ញុំគប់បណ្ដោយ ទៅបណ្ដោយ

541- សូម្ប៉ារ៉ា : អញ្ចឹងៗ ពីនេះទៅ ដើរមកនេះមក អញ្ចឹងមានន័យថា...លោកឯងឈប់ត្រង់នេះណោះ ?

542- ឆាយវី : បាទ !

543- សូម្ប៉ារ៉ា : រួចហើយ ដើរទៅក្រោមដើមអំពិល ឃើញម៉ូតូមួយបោះក្រដាស

544- ឆាយវី : បាទ !

545- សូម្ប៉ារ៉ា : ឃើញប្រេស៊ីលគប់ លោកឯងដើរមកនេះ លោកឯងគប់ដែរ

546- ឆាយវី : បាទ !

547- សូម្ប៉ារ៉ា : អញ្ចឹង លោកឯងឈរប្រហែលខ្ទង់កន្លែងនេះ នៅពេលដែលឈរគប់គ្រាប់បែក

548- ឆាយវី : ខ្ញុំគប់មកខាងសួននោះវិញ

549- សូម្ប៉ារ៉ា : បោះអាគ្រាប់បែកទៅរកសួន អត់បោះមករក...?

550- ឆាយវី : ទេ ! អត់មានបោះមកខាងៗ...

551- សូម្ប៉ារ៉ា : ចុះក្រែងថា អាក្រដាសហ្នឹងជាគោលដៅ ?

552- ឆាយវី : គោលដៅ ! ប៉ុន្ដែ គ្រាន់តែឮភឹងៗហ្នឹងខ្ញុំដូចជាល្ងើ ចេះតែទៅៗហើយ សំដៅទៅខាងនោះ មិនមែនតម្រង់ទៅឯណា

553- សូម្ប៉ារ៉ា : អញ្ចឹង ពេលដែលលោកឯងបោះហ្នឹង លោកឯងឈរនៅកន្លែងសួនច្បារ មិនមែនឈរនៅក្រោមដើមអំពិលទេណោះ ?

554- ឆាយវី : ពេលបោះ ខ្ញុំនៅឈរនៅក្រោមដើមអំពិល

555- សូម្ប៉ារ៉ា : លោកឯងឈរក្រោមដើមអំពិល ហើយបោះទៅរកសួនច្បារវិញ

556- ឆាយវី : សួនច្បារវិញ ប៉ុន្ដែគោលដៅគេថាមួយប្លុកហ្នឹងយើងចាំបាច់នេះធ្វើអ្វី គេថាអោយតែផ្ទុះហ្នឹងណា

557- សូម្ប៉ារ៉ា : អញ្ចឹងមានន័យថា លោកឯងអត់បានបោះតាមបញ្ជាគេទេណា

558- ឆាយវី : អត់តាមទេ...

559- អ៊ាង : បញ្ជាហ្នឹង...

560- ឆាយវី : ...គេថា អោយតែផ្ទុះ

561- អ៊ាង : ការពិតគេបោះក្រដាសនេះទៅ បានឃើញប្រេស៊ីលបោកចំ អាចំណុចហ្នឹងទេ

562- សូម្ប៉ារ៉ា : តែប្រេស៊ីលបោកទៅតាមរកក្រដាសគេនោះមែន...

563- អ៊ាង : ហើយគាត់ គាត់អត់ឃើញអាក្រដាស អត់ចាប់អារម្មណ៍...

564- សូម្ប៉ារ៉ា : ប៉ុន្ដែក្រែងឃើញក្រដាសធ្លាក់ដែរ ?

565- ឆាយវី : ខ្ញុំឃើញក្រដាសហ្នឹងដែរ ប៉ុន្ដែខ្ញុំឃើញក្រដាសហ្នឹងភឹងៗតែម្ដង ខ្ញុំក៏គេចខ្លួនខ្ញុំដែរ ដល់ពេលបោះទៅខាងសួនច្បារឯណោះ វាលមិនមែននៅខាងណេះទេ

566- សូម្ប៉ារ៉ា : បោះទៅកន្លែងសួនច្បារ រួចហើយបានលោកឯងរត់ពីនេះទៅអញ្ចឹង

567- ឆាយវី : បាទ ! រត់ទៅវត្តហើយមានឃើញទាហានគេយាមមួយជួរខាងនេះ

568- អ៊ាង : ហើយអ្នកដែលតាមឃ្លាំឆាយវីឯងមានរត់ដែរទេ ?

569- ឆាយវី : បាត់ហើយពេលនោះ បាត់ហើយបាត់ពេលបោកហើយ

570- អ៊ាង : អរគុណ ! ឆាយវី